

# Where is the Horizon?

## Trafficked on Fishing Vessels

© Environmental Justice Foundation



# តើជើងមេឃនៅឯណា?

## អំពើជួញដូរមនុស្សនៅលើទូកនេសាទ

© Environmental Justice Foundation

ការបោះពុម្ពផ្សាយរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជំណាក់កាលទី២នេះ អាចធ្វើទៅបានដោយមានជំនួយសប្បុរសពីសំណាក់ប្រជាជនអាមេរិក តាមរយៈភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)។ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជំណាក់កាលទី២ កំពុងអនុវត្តដោយអង្គការវីនរ៉ក់អន្តរជាតិ ។

គំនិតយោបល់ទាំងនេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) រដ្ឋាភិបាលអាមេរិក ឬអង្គការវីនរ៉ក់អន្តរជាតិឡើយ។

**This publication of Counter Trafficking in Persons Program (CTIP II) is made possible by the generous support of the American people through the United States Agency for International Development (USAID). CTIP II is implemented by Winrock International.**

The opinions expressed herein do not necessarily reflect the views of USAID, the United States Government or Winrock International.

សម្រាប់ពលករចំណាកស្រុកដែលត្រូវគេបោកឲ្យ
ទៅធ្វើការលើទូកនេសាទ ត្រូវទទួលបានយុត្តិធម៌

កម្រងរឿងខ្លីៗដែលជាបទពិសោធន៍
របស់ជនរងគ្រោះនៅលើទូកនេសាទ

**ឈ្មោះអ្នកនិពន្ធ**
កាមីល ឌូម៉ុន
សារ៉ា ភីហ្សាណូ
ឡូរ៉ា រូម៉ា

**បកប្រែជាភាសាខ្មែរនិងពិនិត្យ**
លោក សៅ កុសល
ក្រុមបុគ្គលិកគម្រោង CTIP II

**ការចងក្រងករណីសិក្សា**
លោក ឆុន រាសី
លោក យា ចិន្តាខន្តី
លោក មុំ សុខចារ

**បោះពុម្ពផ្សាយ**
គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
ដំណាក់កាលទី២ (CTIP II)
អាគារ F បន្ទប់លេខ ៧៨៧ មជ្ឈមណ្ឌលភ្នំពេញ
មហាវិថីសុធារស រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

**សិទ្ធិក្នុងការបោះពុម្ពផ្សាយ**
គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
ដំណាក់កាលទី២ ឆ្នាំ ២០១៤

# *សេចក្តីថ្លែងអំណរគុណ*

ការបោះពុម្ពផ្សាយនេះគឺជាកម្រងករណីសិក្សារបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅលើទូកនេសាទ។ កូនសៀវភៅនេះលើកឡើងពីរឿងរ៉ាវជាសក្ខីភាពចំនួន ១០ ករណី ហើយវាជាប្រត្យក្សភាពតែមួយគត់ ក្នុងគោលបំណងផ្តល់ដល់អ្នកអានឲ្យបានយល់ច្បាស់លើគ្រប់ចំណុចទាំងអស់អំពីអំពើជួញដូរបុរសកម្ពុជាលើទូកនេសាទ។ឈ្មោះជនរងគ្រោះដែលបាន ធ្វើសំភាសន៍ ត្រូវលាក់ទុកដើម្បីរក្សាឲ្យបាននូវឯកជនភាព និងសុខសុវត្ថិភាព។

ការប្រមូលចងក្រងករណីសិក្សាទាំងនេះ គឺជាលទ្ធផលនៃការខិតខំចងក្រងឯកសាររបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២ ដែលត្រូវអនុវត្តដោយអង្គការវីនរ៉ក់អន្តរជាតិ ក្រោមជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ។

អង្គការវីនរ៉ក់អន្តរជាតិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការជំនួយផ្នែកច្បាប់សម្រាប់ស្ត្រី និងកុមារ (LSCW) ដែលជាដៃគូរអនុវត្ត

គម្រោង CTIP II ដែលបានប្រមូលករណីសិក្សាដូចដែលបានរាយការណ៍ក្នុងឯកសារនេះក៏ដូចជាទិន្នន័យដែលបានដាក់ក្នុងសេចក្តីផ្តើម។ ដោយទទួលបានការគាំទ្រថវិកាពីគម្រោង CTIP II អង្គការជំនួយផ្នែកច្បាប់សំរាប់ស្ត្រីនិងកុមារ បានផ្តល់សេវាផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះបានចំនួន៩៧នាក់ ដែលបានដាក់ពាក្យប្តឹងក្រុមហ៊ុនជ្រើសរើសពលករឈ្មោះ Giant Ocean International Fishery Co., Ltd នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវគេស្គាល់ថាជាក្រុមហ៊ុន Giant Ocean។

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរដល់ USAID ចំពោះការផ្តល់ជំនួយហិរញ្ញវត្ថុនិងការគាំទ្រទូទៅ ក្នុងការប្រមូលករណីជួញដូរមនុស្សលើទូកនេសាទនេះ។

ជាចុងក្រោយ យើងសូមថ្លែងអំណរគុណដ៏ស្មោះចំពោះជនរងគ្រោះទាំងអស់ និងញាតិសន្តានរបស់ពួកគេ ដែលមានសេចក្តីក្លាហានក្នុងការចែករំលែករឿងរាវទាំងឡាយជាមួយយើង ហើយយល់ព្រមបង្ហាញពីទុក្ខសោក និងបទពិសោធន៍ជាមួយមិត្តអ្នកអានទូទៅ ។

អង្គការវីនរ៉ក់អន្តរជាតិសូមស្វាគមន៍ក្នុងការប្រើព័ត៌មាននៅក្នុងឯកសារនេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ បន្ត និងប្រើប្រាស់ជាមាគ៌ាសំរាប់គំនិតផ្តួចផ្តើមនានាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**សារ៉ា ភីហ្សាណូ**
**ប្រធានគម្រោង**
**គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**ដំណាក់កាលទី២ (CTIP II)**
**អង្គការវីនរ៉ក់អន្តរជាតិ**

## *សេចក្តីផ្តើម ស្តីពីអំពើជួញដូរបុរសកម្ពុជាលើទូកនេសាទ*

រៀងរាល់ឆ្នាំ គេបានប៉ាន់ប្រមាណថា មានបុរសកម្ពុជារាប់រយនាក់ត្រូវបានគេជួញដូរទៅធ្វើការលើទូកនេសាទនៅក្នុងប្រទេសថៃ។ ជនរងគ្រោះទាំងនោះ ស្ទើតែ ១០០% មកពីជនបទ ដែលរស់នៅក្នុងភាពក្រីក្រ និងខ្វះនូវឱកាសការងារជារៀងរាល់ថ្ងៃ។ ពួកគេមានការស្រេកឃ្លានក្នុងការរកការងារធ្វើ និងសំរេចបូជាជីវិតចំពោះគ្រួសារ ដែលធ្វើឲ្យពួកគេប្រឈមនឹងហានិភយ័ខ្ពស់ក្នុងការដែលអាចងាយធ្លាក់ទៅក្នុងអន្ទាក់ឈ្មួញជួញដូរមនុស្ស។

អ្នកនេសាទទាំងនោះត្រូវក្រុមឈ្មួញជួញដូរមនុស្សដែលមានចិត្តសាហាវឃោឃៅជួញដូរ។ រឿងរ៉ាវគ្រប់យ៉ាង ចាប់ផ្តើមឡើងពីមេខ្យល់នៅក្នុងប្រទេសកម្ពុជា ដែលជាអ្នកនាំជនរងគ្រោះទៅឲ្យជនម្នាក់ទៀតដើម្បីជួយសំរបសំរួលឆ្លងកាត់ព្រំដែនថៃ។ ជាលទ្ធផល ជនរងគ្រោះទាំងអស់ត្រូវធ្លាក់ទៅក្នុងស្ថានភាពត្រូវគេកេងប្រវ័ញ្ចលើទូកនេសាទ។ នៅក្នុងទូកពួកគេដូចជាទាសករជាប់ក្នុងទ្រុង ដោយធ្វើការមិនមានម៉ោងសម្រាក មិនបានទទួលប្រាក់ខែ ធ្វើការងារលំបាកៗ និង ត្រូវថៅកែ នយោជក ឬម្ចាស់ទូករំលោភបំពាន ។ នៅពេលដែលពួកគេរៀបចំគម្រោងរត់គេចខ្លួនចេញពីស្ថានភាពដ៏អាក្រក់នេះ ពួកគេទាំងនោះ ក៏ប្រឈមជាមួយនឹងហានិភ័យក្នុងការដែលអាជ្ញាធរនៃប្រទេសគោលដៅចាប់ខ្លួន ឃុំខ្លួន និងបញ្ជូនត្រឡប់មកប្រទេសខ្លួនវិញ ដោយសារតែពុំមានឯកសារបញ្ជាក់អត្តសញ្ញាណ ឬឯកសារធ្វើដំណើរ។

រូបភាពនៃអំពើជួញដូរបុរសកម្ពុជាលើទូកនេសាទមានការវិវត្តទៅតាមពេលវេលា។ កាលពីមុន រូបភាពនៃអំពើជួញដូរមនុស្សត្រូវធ្វើឡើងតាមបណ្តាញខុសច្បាប់ គឺធ្វើតាមរយៈមេខ្យល់តែប៉ុណ្ណោះ។ ប៉ុន្តែក្នុងពេលថ្មីៗនេះ វាបានប្តូររូបរាងទាំងស្រុង ៖ ករណីជួញដូរបុរសកម្ពុជាទៅធ្វើ

ការលើទូកនេសាទត្រូវបានធ្វើឡើង តាមរយៈបណ្ដាញស្របច្បាប់ ពោល គឺក្រុមហ៊ុនជ្រើសរើសពលករ ដែលត្រូវគេបង្កើនការចងក្រងឯកសារទុក និងត្រូវផ្សព្វផ្សាយឲ្យសាធារណជនបានដឹង។

### *អំពីក្រុមហ៊ុន GIANT OCEAN INTERNATIONAL FISHERY CO., LTD. (Giant Ocean)*

ក្រុមហ៊ុន Giant Ocean[1] គឺជាក្រុមហ៊ុនជ្រើសរើសពលករមួយដែលមានការរកស៊ីហ៊ុនគ្នារវាង ជនជាតិតៃវ៉ាន់ និងកម្ពុជា ហើយក្រុមហ៊ុនជ្រើសរើសពលករនេះគ្រប់គ្រង និងដឹកនាំដោយជនជាតិតៃវ៉ាន់ ដែលការិយាល័យធំ ស្ថិតនៅរាជធានីភ្នំពេញ។ ក្រុមហ៊ុន Giant Ocean បានចុះបញ្ជីនៅក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈកម្ពុជា នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១០ ក្នុងគោលបំណង “ ជ្រើសរើស និង បញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ថៃ ជប៉ុន និង គូវ៉ែត”[2] ប៉ុន្តែស្ទើរតែគ្មានពលករខ្មែរដែលបានជ្រើសរើសណាម្នាក់ត្រូវគេបញ្ជូនទៅប្រទេសទាំងនោះទេ ផ្ទុយទៅវិញ ពួកគេភាគច្រើនត្រូវបញ្ជូនទៅប្រទេសឆ្ងាយៗ ដូចជា អាហ្វ្រិកខាងត្បូង សេណេហ្គាល់ ហ្វីជី និងប្រទេសម៉ូរីទូស ។

ទោះបីជាមិនមានការហាមឃាត់ជាផ្លូវការក្នុងការជ្រើសរើស និងបញ្ជូនពលករកម្ពុជាទៅធ្វើការលើទូកនេសាទនៅបរទេសយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្ដីថ្លែងការណ៍ជាច្រើនលើកច្រើនសារ

[1] មានក្រុមហ៊ុនជ្រើសរើសពលករចំនួនពីរផ្សេងទៀត ក៏បានចូលរួមក្នុងការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅធ្វើការលើទូកនេសាទនៅបរទេសផងដែរ ក្រោមរូបភាពជាភ្នាក់ងារ ឬជាតំណាងឲ្យក្រុមហ៊ុន Giant Ocean គឺក្រុមហ៊ុន Phoenix International Co., Ltd និងក្រុមហ៊ុន Hao Yuen International Co., Ltd ។

[2] ក្រុមហ៊ុន Giant Ocean ក៏បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ក្នុងការបញ្ជូនសារប្រាប់សាធារណជនឲ្យបាន ជ្រាបថា រាជរដ្ឋាភិបាល មិនអនុគ្រោះចំពោះសកម្មភាពបែបនេះទេ។ ទោះបីជាមានការបញ្ជាក់ពីរាជរដ្ឋាភិបាលកម្ពុជាបែបនេះក៏ដោយ ក៏សារព័ត៌មានជាច្រើននៅតែរាយការណ៍ថា ក្រុមហ៊ុន Giant Ocean បានបញ្ជូនពលករកម្ពុជាជាបុរសជាង ១០០០នាក់ ដោយរលូន ទៅធ្វើការលើទូកនេសាទនៅក្រៅប្រទេស[3] ដោយរំលោភលើអាជ្ញាបណ្ណ័ដែលទទួលបានពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការអនុញ្ញាតឲ្យក្រុមហ៊ុននេះ ជ្រើសរើស និងបញ្ជូនពលករទៅប្រទេសដែលបានរៀបរាប់ខាងលើតែប៉ុណ្ណោះ ហើយជាពិសេសមិនមែនការងារបិតក្នុងឧស្សាហកម្មនេសាទទៅទៀត[4] ។ គ្រួសាររបស់ពួកពលករបានរាយការណ៍ពីការបាត់ខ្លួនពលករជាបុរសរាប់រយនាក់ និងពលករដែលបានធ្វើមាតុភូមិនិវត្តន៍មកកាន់កម្ពុជាវិញ ក៏ត្រូវអង្គការដែលជាដៃគូរអនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២ កំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សរួចរាល់ជាស្រេច ហើយដែលអង្គការដៃគូទាំងនោះ ទទួលបានជំនួយហិរញ្ញវត្ថុពី USAID ទីភ្នាក់ងារអង្គការសហប្រជាជាតិនានា និង/ឬ អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ។

---

[3] កាសែតខេមបូឌាដេលី បានចុះផ្សាយកាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១២ ថា “ មានពលករនេសាទខ្មែរជាបុរស ដែលត្រូវគេជួញដូរទៅធ្វើការនៅប្រទេសអាហ្វ្រិកខាងត្បូង បានវិលត្រឡប់មកផ្ទះវិញហើយ” : ប្រធានសមាគមន៍នៃក្រុមហ៊ុនជ្រើសរើសពលករខ្មែរ ហៅកាត់ថា ACRA បានរាយការណ៍ថា ក្រុមហ៊ុន Giant Ocean បានបញ្ជូនពលករខ្មែរប្រមាណជា ១០០០នាក់ បានទៅធ្វើការនៅក្រៅប្រទេស ។

[4] ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជិវៈបានថ្លែងមិនផ្លូវការថា ក្រសួងបានដក និង ព្យួរអាជ្ញាបណ្ណ័រកស៊ីនៅកម្ពុជារបស់ក្រុមហ៊ុន Giant Ocean រងចាំសេចក្តីសំរេចចុងក្រោយរបស់តុលាការកម្ពុជា ។ ការិយាល័យរបស់ក្រុមហ៊ុននេះ នៅទីក្រុងភ្នំពេញ ត្រូវបិទទ្វារ ហើយប្រតិបត្តិការរបស់ក្រុមហ៊ុននេះ ត្រូវផ្អាកជាស្ថាពរដោយសារអវត្តមានរបស់អ្នកគ្រប់គ្រងរបស់ខ្លួនចំនួនពីរនាក់ គឺលោក លូ លាន តេ និងលោកស្រី លីន លី ចិន ។ លោក លូ លាន តេ ត្រូវគេសន្មត់ថាជាប្រធានក្រុមហ៊ុន ហើយលោកស្រី លីន លី ចិន ជាអនុប្រធានក្រុមហ៊ុន។

ក្នុងត្រីមាសទី១ ឆ្នាំ២០១២ ចំនួនបណ្តឹងត៉វ៉ាពីក្រុមគ្រួសារពលករជាបុរសមានការកើនឡើងគួរឲ្យកត់ ត្រូវធ្វើការរួមគ្នាក្នុងការចងក្រងទិន្នន័យ សំរាប់រៀបចំរបាយការណ៍ដំបូងអំពីស្ថាភាពពលករនេសាទកម្ពុជានៅប្រទេសអាហ្វ្រិក[5] ។ នៅពេលនោះ មានទីភ្នាក់ងារមួយដែលជួយការងារនេះ បានរាយការណ៍ថា ខ្លួនបានទទួលការស្នើរសុំឲ្យជួយពលករចំនួន២៥នាក់ ដែលធ្វើការនៅក្រៅប្រទេស ពេលដែលទីភ្នាក់ងារមួយផ្សេងទៀតបានរាយការណ៍ថា គ្រួសារពួកគេបានស្នើរសុំឲ្យទីភ្នាក់ងារនោះជួយអន្តរាគមន៍ពលករចំនួន២៦នាក់ផ្សេងទៀត ដែលបាត់ខ្លួននៅឡើយក្នុងពេលទៅធ្វើការនៅក្រៅប្រទេស ។ មានគ្រួសារពលករប្រហែលពាក់កណ្តាលបានដាក់ពាក្យប្តឹងជាផ្លូវការទៅមន្ត្រីនគរបាលមូលដ្ឋានក្នុងខេត្តកំពង់ឆ្នាំងនៃប្រទេសកម្ពុជា។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ដោយក្រសួងនីមួយៗបានរាយការណ៍ថា មានចំនួនករណីចន្លោះពី១៧០នាក់ ទៅ២០០នាក់ ទាក់ទងនឹងពលករនេសាទជាបុរស ហេតុនេះ យើងមិនបានដឹងច្បាស់អំពីទិន្នន័យដែលត្រួតស៊ីគ្នានេះទេ ។

ក្នុងខែឧសភា ឆ្នាំ២០១២ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ) បានរៀបចំកិច្ចប្រជុំពិភាក្សាយ៉ាងតឹងតែងជាលើកដំបូង រវាងអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាល ស្តីពីក្រុមហ៊ុន Giant Ocean និងការកើនឡើងនូវចំនួនពលករនេសាទខ្មែរ ដែលត្រូវគេរាយការណ៍ថា បានទៅធ្វើការលើទូកនេសាទចិនតៃវ៉ាន់នៅប្រទេសអាហ្វ្រិក[6] ។ ក្រសួងនានា និងប្រធានអង្គការ Chab Dai[7]

---

[5] ឯកសារ ស្តីពីអង្គហេតុនៃករណីនេះ ចុះកាលបរិច្ឆេទខែមីនា ឆ្នាំ២០១២ ត្រូវចែកជូនអាជ្ញាធរប្រទេសអាហ្វ្រិកខាងត្បូង និងអង្គការសង្គមស៊ីវិល ដើម្បីជ្រាបជាព័ត៌មាន ។

បានចាត់វិធានការជាជំហានៗក្នុងការរៀបចំបញ្ចូលករណី ទៅក្នុងដំណើរការបញ្ជូនពលករឲ្យបានរហ័យ ដោយក្រសួងផ្សេងៗ និងប្រធានអង្គការ Chab Dai បានសង្កត់ធ្ងន់ពីសេចក្តីត្រូវការក្នុងការសុំឲ្យក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជំរុញឲ្យមានការចូលរួមពីរដ្ឋាភិបាលអាហ្វ្រិកខាងត្បូងក្នុងការដោះស្រាយករណីក្រុមហ៊ុន Giant Ocean នេះ ។ ការប្រជុំនេះ ក៏បានកំណត់នូវចំណុចចាប់ផ្តើមនៃការបន្តកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសង្គមស៊ីវិលខ្មែរ ក្នុងការទាមទារការទូទាត់សំណងឲ្យជនរងគ្រោះដោយសារក្រុមហ៊ុន Giant Ocean ពីកញ្ចប់ប្រាក់ធានារបស់ក្រុមហ៊ុនដែលបានតំកល់ទុកនៅ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ[8] ដែលមានទឹកប្រាក់ចំនួន ១០០,០០០.០០ ដុល្លារអាមេរិក។ រហូតមកដល់ពេលនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទាន់មានយន្តការណាមួយក្នុងការដកប្រាក់កក់នេះ យកទៅសងពលករចំណាកស្រុកដែលត្រូវគេបោកប្រាស់នៅឡើយទេ[9] ។

---

[6] ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ លោកជំទាវ ជូ ប៊ុនអេង ។ ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ នេះ គឺឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

[7] អង្គការ Chab Dai ជាសម្ព័ន្ធអង្គការមួយដែលមានការចូលរួមគ្នាពីអង្គការក្រៅរដ្ឋាភិបាលចំនួន ៥៨ ធ្វើការរួមគ្នាក្នុងលុបបំបាត់ការជួញដូរមនុស្ស និងការរំលោភផ្លូវភេទ ។

[8] ផ្អែកតាមអនុក្រឹត្យលេខ ១៩០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រាក់ចំនួន ១០០,០០០.០០ ដុល្លារអាមេរិក ជាប្រាក់តំកល់ទុកជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធានាទូទាត់សំណងដល់ជនរងគ្រោះ នៅពេលដែលក្រសួងចេញអាជ្ញាបណ្ណ័ឲ្យក្រុមហ៊ុនជ្រើសរើសពលករណាមួយ ។

[9] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងធ្វើការជាមួយអង្គការការងារអន្តរជាតិ (ILO) ក្នុងការរៀបចំប្រកាសមួយ ស្តីពី ការប្រើប្រាស់ប្រាក់តំកល់របស់ក្រុមហ៊ុនជ្រើសរើសពលករ ។

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និង ទីភ្នាក់ងារអង្គការសហប្រជាជាតិនានា បានមើលឃើញពីកំណើនយ៉ាងលឿននូវចំនួនជនរងគ្រោះដែលបានធ្វើមាតុភូមិនិវត្តមកកម្ពុជា ចាប់តាំងពីមានការរាយការណ៍ជាលើកដំបូង ស្តីពីក្រុមហ៊ុន Giant Ocean ក្នុងខែមីនា ឆ្នាំ២០១២ មក ។ រឿងដ៏សោកសៅរបស់ពួកគេបង្ហាញពីរូបភាពនៃការបោកប្រាស់ និង ការរំលោភបំពានជាប្រព័ន្ធ ដោយស្នាដៃជនជាតិចិនតៃវ៉ាន់ និងកម្ពុជា[10] ។ ពេលថ្មីៗនេះ នៅក្នុងខែសីហា ឆ្នាំ២០១២ ជនរងគ្រោះដោយសារក្រុមហ៊ុន Giant Ocean បានផ្តល់នូវឯកសារភស្តុតាងសំខាន់ៗជាលើកដំបូង ដែលបានភ្ជាប់ក្រុមហ៊ុន Giant Ocean ទៅនឹងក្រុមហ៊ុនសិង្ហបុរីមួយដែលមានឈ្មោះថា Step-Up Marine Enterprise (Step-Up) ពិតប្រាកដមែន ហើយក្រុមហ៊ុននេះ ត្រូវគេចោទប្រកាន់ថាបានរួមចំណែកជ្រើសរើសពលករ និងជួញដូរពលករនេសាទខុសច្បាប់តាំងពីឆ្នាំ១៩៨៧ មកម្លេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ទំនាក់ទំនងរវាងក្រុមហ៊ុន Giant Ocean ក្រុមហ៊ុន Step-Up ក្រុមហ៊ុននេសាទចិនតៃវ៉ាន់ និងម្ចាស់ទូកនេសាទនៅមានភាពមិនច្បាស់លាស់នៅឡើយទេ។ ឯកសារ និងសាក្ខីកម្មរបស់ជនរងគ្រោះដែលមានភាពក្លាហាន បានផ្តល់នូវមូលដ្ឋានដ៏រឹងមាំសម្រាប់ការបើកការស៊ើបអង្កេតរកជនល្មើសដែលបានប្រព្រឹត្តនេះក្នុងប្រទេសចិនតៃវ៉ាន់ និងប្រទេសសិង្ហបុរី ។

[10] លិខិតឆ្លងដែនរបស់អនុប្រធានក្រុមហ៊ុន Giant Ocean បញ្ជាក់ឲ្យដឹងថា នាងជាជនជាតិចិនតៃវ៉ាន់ ហើយលិខិតអនុញ្ញាតឲ្យបើកក្រុមហ៊ុនដែលចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា ប្រធានក្រុមហ៊ុន ក៏ជាជនជាតិចិនតៃវ៉ាន់ដែរ ហើយតាមរយៈឯកសារភស្តុតាង និងសក្ខីកម្មជនរងគ្រោះ បានឲ្យក្រុមការងារកម្ពុជាសម្រាប់ពលករនេសាទចំណាកស្រុកដឹងថា ម្ចាស់ទូកនេសាទភាគច្រើនទំនងជាជនជាតិចិនតៃវ៉ាន់ដែលបានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ វាទាមទារឲ្យមានការស៊ើបអង្កេតបន្ថែមទៀត ព្រោះថាវាអាចនឹងមានក្រុមហ៊ុនចិនតៃវ៉ាន់ផ្សេងៗទៀត ក៏បានចូលរួមពាក់ព័ន្ធនឹងរឿងជួញដូរមនុស្សនេះផងដែរ ។

## *ការកាត់ទោសក្រុមហ៊ុន Giant Ocean*

ករណីរបស់ក្រុមហ៊ុន Giant Ocean ត្រូវគេបានរាយការណ៍ជាសាធារណៈ នៅចុងឆ្នាំ២០១១ បន្ទាប់ពីគ្រួសាររបស់កម្មករដែលបានបញ្ជូនពួកគេទៅធ្វើការតាមរយៈក្រុមហ៊ុននេះ បានស្នើសុំឲ្យរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ជួយបងប្អូនជាទីស្រឡាញ់របស់គេ ដែលកំពុងធ្វើការនៅក្នុងលំហរសមុទ្រ និងនៅពេលដែលក្រុមហ៊ុន Giant Ocean បានបិទទីស្នាក់ការក្នុងក្រុងភ្នំពេញ ហើយអ្នកគ្រប់គ្រងក្រុមហ៊ុនបានរត់គេចខ្លួនបាត់ ។

នាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនិតិជន ខេត្តសៀមរាប ចាប់បានខ្លួនអ្នកគ្រប់គ្រងក្រុមហ៊ុន Giant Ocean លោកស្រី លីន លី ចិន ក្នុងខែឧសភា ឆ្នាំ ២០១៣ នៅឯខេត្តសៀមរាប តាមដីការចាប់ខ្លួន ចេញដោយតុលាការក្រុងភ្នំពេញ ដោយជាប់ចោទពីបទនាំមនុស្សចេញខុសច្បាប់ដោយមានគោលដៅ ដោយយោងតាមមាត្រា១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ ។ តុលាការបានចំណាយពេលស្ទើរតែមួយឆ្នាំ ដើម្បីស៊ើបអង្កេតនិងដំណើរការ និតិវិធីតុលាការ មុននឹងនាំទៅដល់ការកាត់ទោស និងចេញសេចក្តីសំរេច។

សវនាការលើកទីមួយបានកំណត់នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១៤ និងលើកទីពីរនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៤ ហើយសវនាការចុងក្រោយនៅថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១៤ ។ បន្ទាប់ពីបើកសវនាការទាំងបីលើក តុលាការបានប្រកាសសាលក្រមនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៤ដាក់ឲ្យជនជាប់ចោទចំនួន៦នាក់ ជាប់ពន្ធនាគាររយៈពេល១០ឆ្នាំ ហើយជនរងគ្រោះទាំងអស់ត្រូវតែទទួលបានសំណងចំពោះការខូចខាត ។

ប៉ុន្តែនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៤ ឧក្រិដ្ឋជន លីន លី ចិន បានប្តឹង

ជំទាស់ទៅសាលាឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសំរេចរបស់តុលាការ ដើម្បីពន្យាពេលដំណើរការទូទាត់ប្រាក់សំណង ។

បច្ចុប្បន្ននេះ មេធាវីរបស់អង្គការមិនមែនរដ្ឋាភិបាល មិនមានលទ្ធភាពទទួលបានឯកសារសាលក្រម របស់តុលាការ ដើម្បីផ្ទៀងផ្ទាត់ឈ្មោះកូនក្ដីដែលមិនបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីរសំរាប់ទទួលបានសំណងទេ ។ អង្គការដៃគូររបស់គម្រោង CTIP II គឺអង្គការជំនួយផ្នែកច្បាប់សម្រាប់ស្ដ្រីនិងកុមារ កំពុងតែបន្តធ្វើការលើរឿងនេះនៅសាលាឧទ្ធរណ៍ ។

# ករណីសិក្សា

## ប្រទេសសេណេហ្គាល់

| | |
|---|---|
| ចំនួនជនរងគ្រោះ និងស្រុកកំណើត | ជនរងគ្រោះ ៤នាក់ មកពីភ្នំពេញ កំពង់ធំ ក្រចេះ និងកំពង់ចាម |
| ទិសដៅ | ប្រទេសសេណេហ្គាល់ |
| ថ្ងៃចេញដំណើរ | ០៥ ខែសីហា ឆ្នាំ២០១០ |
| ថ្ងៃវិលត្រឡប់ | ០៤ ខែមេសា ឆ្នាំ ២០១២ និង ២០ ខែឧសភា ឆ្នាំ ២០១២ |
| ប្រាក់ខែដែលសន្យា | ១៣០ ដុល្លារអាមេរិកក្នុងមួយខែ + ប្រាក់បន្ថែម 500 - 2,000 ដុល្លាអាមេរិក រៀងរាល់៣ខែ |
| ប្រាក់ខែទទួលបានសរុប | ៥០០ ដុល្លារអាមេរិក និងថ្លៃសំបុត្រយន្តហោះមកកម្ពុជាវិញ |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរមនុស្សឆ្លងដែនដើម្បីកេងប្រវ័ញ្ចពលកម្ម<br>- គ្មានទទួលប្រាក់ខែ<br>- រំលោភបំពានដល់រាងកាយ<br>- ខ្វះអាហារ<br>- ធ្វើការ ២០ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ |
| ភ្នាក់ងារជ្រើសរើស | ក្រុមហ៊ុន Giant Ocean International |
| ថ្ងៃខែបំពេញពាក្យបណ្តឹង | ២៥ កញ្ញា ឆ្នាំ ២០១២ |
| សំណងដែលទាមទារ | ៥០០០ដុល្លារអាមេរិកក្នុងមួយនាក់ |

| | |
|---|---|
| សេវាដែលទទួលការគាំទ្រពី CTIP II | - ផ្ដល់សេវាផ្នែកច្បាប់ និង ពិគ្រោះយោបល់<br>- ជួយជនរងគ្រោះទៅសម្ភាសន៍ និងដាក់ពាក្យបណ្ដឹងទៅនាយកដ្ឋានយុត្តិធម៌ និងប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ<br>- ផ្ដល់ជំនាញជួសជុលម៉ូតូតាមរយៈអង្គការស្ត្រីខ្មែរសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ |

ករណីនេះទាក់ទងនិងបុរសជនជាតិកម្ពុជា ៦នាក់ ដែលត្រូវបានគេជួញដូរពីប្រទេសកម្ពុជាទៅប្រទេសអ៊ីរ៉ុីខូស និងសេណោហ្គាល់ ហើយបង្ខំឲ្យធ្វើការងារនេសាទលើកប៉ាល់ជនជាតិតៃវ៉ាន់។ បុរសទាំងនោះ បានធ្វើការ រយៈពេល ២០ខែ តែគេមិនដឹងច្បាស់ថាដែនទឹកដែលកប៉ាល់កំពុងឋិតនៅនោះជាប្រទេសណាឡើយ។

បុរស៤នាក់បានវិលត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២ ហើយនៅសល់ ២នាក់ទៀត បានវិលត្រឡប់មកវិញដោយទិញសំបុត្រយន្តហោះខ្លួនឯង នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១២។ ករណីសិក្សានេះ គឺបានមកពីការសម្ភាសន៍ជាមួយបុរសម្នាក់ក្នុងចំណោមបុរស ៤នាក់ ដែលត្រឡប់មកកម្ពុជាវិញ។ រីឯអ្នកធ្វើមាតុភូមិនិវត្ត ៣នាក់ផ្សេងទៀត បានបញ្ជាក់ថា រឿងរបស់ពួកគេដូចគ្នានឹងជនរងគ្រោះដែលបានសម្ភាសន៍ (ជនរងគ្រោះ) អញ្ចឹង។

## ការជ្រើសរើស

ជនរងគ្រោះបានអានកាសែតកោះសន្តិភាព ដែលប្រកាសជ្រើសរើស អ្នកធ្វើការងារនេសាទ កាលពីខែកក្កដា ឆ្នាំ២០១០ កន្លងទៅ ។ ការប្រកាសតាមវិទ្យុពីការងារនោះ (គាត់មិនចាំវិទ្យុមួយណាទេ) គឺជាការប្រកាសពត៌មានទូទៅប៉ុណ្ណោះ។ ក្រោយពីបានឮពត៌មាននោះ គាត់បានទាក់ទងមកភ្នាក់ងារជ្រើសរើសពលកររបស់ក្រុមហ៊ុន Giant Ocean និងពិភាក្សាជាមួយ លោក ឆាយ ដែលគេហៅគាត់ថាលោកគ្រូឆាយៗ លោកគ្រូឆាយអាចនិយាយភាសារចិនបាន។ យោងតាមជនរងគ្រោះបានឲ្យដឹងថាលោកគ្រូឆាយជាអ្នកគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនជ្រើសរើសពលករ។ បុរសដែលប្រហែលជាជនជាតិចិន ឬតៃវ៉ាន់បានពន្យល់លក្ខខណ្ឌការងារ និងប្រាក់ខែដល់ជនរងគ្រោះជាភាសារចិន និងបកប្រែជាភាសារខ្មែរដោយលោកគ្រូឆាយ។ ជនរងគ្រោះបញ្ជាក់ថាបុរសជនជាតិចិន ឬតៃវ៉ាន់នោះទំនងជានាយកក្រុមហ៊ុនជ្រើសរើសពលករ។ ភ្នាក់ងារជ្រើសរើសពលករធ្វើកិច្ចសន្យារយៈពេលបីឆ្នាំ ចំពោះការងារនេសាទនេះ។ ដោយសន្យាថាប្រាក់ខែចាប់ផ្តើមពី ១៣០ដុល្លារអាមេរិកក្នុងមួយខែ និងប្រាក់បន្ថែមលើកទឹកចិត្តចំនួន ៥០០ ទៅ២០០០ ដុល្លារអាមេរិក នឹងផ្តល់ឲ្យជនរងគ្រោះរៀងរាល់បីខែម្តង។ ទោះបីជាប្រាក់បន្ថែមលើកទឹកចិត្តអាស្រ័យលើការបំពេញការងាររបស់គាត់ក៏ដោយ ក៏ភ្នាក់ងារជ្រើសរើសពលករ សន្យាជាមួយជនរងគ្រោះថា យ៉ាងតិចណាស់គាត់នឹងទទួលប្រាក់បន្ថែមលើកទឹកចិត្តចំនួន ៥០០ដុល្លារអាមេរិកដែរ រៀងរាល់បីខែ។ ម្យ៉ាងទៀត ភ្នាក់ងារជ្រើសរើសពលករបានប្រាប់ជនរងគ្រោះថានឹងដាក់ចូលក្នុងគណនីធនាគារ SBC ហើយគ្រួសាររបស់គាត់អនុញ្ញាតិ

ឲ្យដកបាន ៥០ដុល្លារអាមេរិកជារៀងរាល់ខែ។ គ្រួសាររបស់គាត់មិនអនុញ្ញាតិឲ្យដកប្រាក់ដែលនៅសល់ ៨០ដុល្លារអាមេរិកក្នុងមួយខែនៃប្រាក់ខែរបស់គាត់ មុនពេលជនរងគ្រោះធ្វើការងារបានមួយឆ្នាំឡើយ។ ទោះបីយ៉ាងណា គណនីនៅធនាគារ SBC មិនត្រូវបានបើកដាក់ឈ្មោះជនរងគ្រោះទេ។ ការពិតគណនីនោះបានត្រូវគេបើកដោយដាក់ឈ្មោះក្រុមហ៊ុន Giant Ocean ហើយគ្រួសារជនរងគ្រោះត្រូវទៅធនាគារជាមួយបុគ្គលិករបស់ក្រុមហ៊ុន ដើម្បីដកប្រាក់រៀងរាល់ខែ។ ក្រោយមក ក្រុមហ៊ុន Giant Ocean បានបិទគណនីនៅធនាគារ SBC ។ ភ្នាក់ងារជ្រើសរើសពលករមិនត្រឹមតែ មិនពន្យល់ពីលក្ខខណ្ឌការងារទេ ថែមទាំងមិនឲ្យដំណឹងដល់ជនរងគ្រោះ ថាគាត់ត្រូវទៅប្រទេសណាដែរ ។ ព័ត៌មានដែលគេប្រាប់គាត់គឺទៅធ្វើការឲ្យក្រុមហ៊ុនតៃវ៉ាន់។ ពួកគេធានាថា គាត់នឹងទទួលបានអាហារ និងសំលៀកបំពាក់គ្រប់គ្រាន់ ហើយគាត់ត្រូវតែនៅធ្វើការឲ្យបានមួយឆ្នាំ មុនពេលគាត់អនុញ្ញាតិឲ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ។

ជនរងគ្រោះយល់ព្រមបង់ប្រាក់ថ្លៃលិខិតឆ្លងដែន និងសៀវភៅកំណត់ត្រាកម្មករនៃសាទ ចំនួន ៣១០ដុល្លារអាមេរិក ទៅឲ្យភ្នាក់ងារជ្រើសរើសពលករ។ ភ្នាក់ងារជ្រើសរើសពលករបានឲ្យជនរងគ្រោះខ្ចីប្រាក់ ១០០ដុល្លារអាមេរិក ដោយពុំមានកិច្ចសន្យាសងប្រាក់នេះវិញទេ សម្រាប់ទិញសំលៀកបំពាក់ និងរបស់របរផ្សេងៗទៀតមុនពេលចេញដំណើរ ។ បន្ទាប់ពីជនជាតិចិន ឬតៃវ៉ាន់ពន្យល់ពីប្រាក់ខែចប់សព្វគ្រប់ ជនរងគ្រោះបានផ្តិតមេដៃលើកិច្ចសន្យា ដែលកិច្ចសន្យានោះហាក់ដូចជាសរសេរជាភាសារចិន ជនរងគ្រោះមិនអាចអាន និងមិនទាមទារឲ្យបក

ប្រែដែរ។ គ្មានជនរងគ្រោះណាមួយដែលពាក់ព័ន្ធក្នុងករណីនេះបានថត ចំលងកិច្ចសន្យានោះទេ។

**ការចេញដំណើរ**

ជនរងគ្រោះបានទៅជួបភ្នាក់ងារជ្រើសរើសពលករដោយខ្លួនឯងផ្ទាល់ ហើយស្នាក់នៅទីនោះ ពីរ សប្តាហ៍មុនពេលចេញដំណើរ។ ការចេញដំណើររបស់គាត់ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០ ដោយក្រុមហ៊ុន Giant Ocean ដឹកឡានជនរងគ្រោះទៅព្រលានយន្តហោះ ក្នុងឡានមានមនុស្ស៥នាក់ ក្នុងនោះមានជនរងគ្រោះម្នាក់ ២នាក់ជាជនជាតិកម្ពុជា ដែលក្រោយមកក៏បានក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្សដែរ (សរុបទាំងអស់មានគ្នាបីនាក់ នៃបុរស៦នាក់ ដែលត្រូវគេជួញដូរទៅប្រទេសសេណេហ្គាល់) ក្នុងឡានម្នាក់ទៀតនោះ ជាជនជាតិចិន ឬតៃវ៉ាន់ (ដែលប្រហែលទំនងជានាយកភ្នាក់ងារជ្រើសរើសពលករ) និងស្ត្រីម្នាក់ ដែលប្រហែលជាប្រពន្ធរបស់បុរសជនជាតិចិនឬតៃវ៉ាន់ក៏ជិះជាមួយដែរ។ នៅព្រលានយន្តហោះ ពុំមានព័ត៌មានផ្តល់ឲ្យជនរងគ្រោះទាំងបីនាក់នោះទេ។

ជនរងគ្រោះបានឈប់រយៈពេលខ្លីនៅទីក្រុងបាងកក និងឌូបៃ មុនពេលពួកគេទៅដល់ប្រទេស អ៊ីវ៉ូរីខូស នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១០។ ជនរងគ្រោះស្នាក់នៅកំពង់ផែដាប៊ីដ្យាន ប្រទេសអ៊ីវ៉ូរីខូស រយៈពេល ៩ថ្ងៃ មុនពេលពួកគេចេញពីកំពង់ផែតទៅទៀតនេះ (ក្នុងប្រទេសអ៊ីវ៉ូរីខូស) នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១០។

## លក្ខខណ្ឌការងារ និងការកេងប្រវ័ញ្ចពលកម្ម

ជនរងគ្រោះធ្វើការងារនេសាទនៅកណ្តាលសមុទ្ររយៈពេល ២០ខែ មុនពេលទូកចូលចតនៅកំពង់ផែ ក្នុងប្រទេសសេណេហ្គាល់។

ទូកមានបណ្តោយ ៦៥ម៉ែត្រ និងទទឹង ១៥ម៉ែត្រ។ មានសមាជិកនេសាទទាំងអស់ ៣០នាក់ ក្នុងនោះកម្ពុជា ៦នាក់ ឥណ្ឌូនេស៊ី ៦នាក់ ហ្វីលីពីន ៧នាក់ វៀតណាម ៧នាក់ ចិន ៤នាក់ និងចុងភៅម្នាក់ជាជនជាតិចិន។ ទូកពណ៌ស មានឈ្មោះថា "ស៊ីន យឿ ស្លាកលេខ១៦" ។ ទូកដាក់ទង់ជាតិអ៊ីវ៉ូរីខូស នៅពេលទូកចតនៅកំពង់ផែដាប៊ីដ្យាន ហើយក៏ដាក់ទង់ជាតិសេណេហ្គាល់ នៅពេលចតនៅកំពង់ផែប្រទេសសេណេហ្គាល់។ នៅពេលទូកស្ថិតនៅកណ្តាលសមុទ្រ គេមិនដាក់ទង់ជាតិប្រទេសណាទេ ធ្វើឲ្យមានការលំបាកក្នុងការប៉ាន់ស្មានថាជាទូករបស់ជនជាតិណាមួយ។ ជនរងគ្រោះមិនដែលបានជួប និងមិនស្គាល់នរណាជាម្ចាស់ទូកឡើយ។

មេក្រុមទូកប្រហែលជាជនជាតិតៃវ៉ាន់ ហើយជនរងគ្រោះមិនស្គាល់ឈ្មោះគាត់ទេ។ គាត់ធ្វើការជាមួយមេក្រុមរង ដែលប្រហែលជាជនជាតិចិន។

ជនរងគ្រោះត្រូវបង្ខំឲ្យធ្វើការ ១៥ម៉ោងក្នុងមួយថ្ងៃ ដោយបានដេកតិចតួចតែប៉ុណ្ណោះ ជួនកាលពួកគេត្រូវបង្ខំឲ្យធ្វើការ ៤៨ម៉ោង ដោយគ្មានសំរាក។ ការងាររបស់ពួកគេនៅលើទូកមានទាំងការងារនេសាទ និងជួសជុលម៉ាស៊ីន។ ជនរងគ្រោះទទួលអាហារបីពេលក្នុងមួយថ្ងៃ ប៉ុន្តែត្រូវហូបឲ្យលឿនបំផុត បើមិនដូច្នោះទេ នឹងត្រូវកម្មករដ៏ទៃទៀតគេហូបអស់។ បើសិនជាពួកគេមកហូបយឺត គឺពុំមានអាហារទុកឲ្យទេ ហើយពួកគេក៏គ្មានអ្វីហូបដែរ។ ពួកគេតែងតែទុកត្រីខ្លះដើម្បីឲ្យបានហូបគ្រប់គ្រាន់។ ពួកគេមានខោអាវតែមួយសម្រាប់ប៉ុណ្ណោះ ជាពិសេសនៅលើទូក។ ពួកគេដេកនៅលើគ្រែតូចៗ ៤នាក់ក្នុងមួយបន្ទប់។

ជនរងគ្រោះបានទទួលប្រាក់ ២០ដុល្លារអាមេរិក ក្នុងមួយខែ ពេលធ្វើការនៅលើទូក។ ពួកគេមិនដែលត្អូញត្អែរពីលក្ខខណ្ឌការងារលំបាកទាំងនោះ ដាក់មេក្រុមទូកទេ ដោយសារពួកគេខ្លាចគាត់វាយធ្វើបាប។ មេក្រុមរងបានវាយធ្វើបាបជនរងគ្រោះបីបួនដង ដោយសារគាត់អស់កម្លាំង។ ជនរងគ្រោះបញ្ជាក់ថា មានកម្មករនេសាទខ្លះ ត្រូវបានវាយធ្វើបាប ដោយសារពួកគេឈ្លោះគ្នា។

ថ្ងៃមួយ បន្ទាប់ពីនៅលើទូកបាន ៤ខែ ជនរងគ្រោះបានពិភាក្សាជាមួយកម្មករផ្សេងទៀត ហើយដឹងថា ពួកគេមិនបានទទួលប្រាក់លើកទឹកចិត្ត ដូចដែលបានសន្យាឲ្យពួកគេទេ ដូច្នេះពួកគេបានសួរទៅមេក្រុមទូក ឲ្យដោះលែងពួកគេពីទូក ដើម្បីពួកគេអាចវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ មេក្រុមទូកបានបដិសេធ ដោយមិនពន្យល់ពីមូលហេតុច្បាស់លាស់។

ពេលជនរងគ្រោះបានឃើញនាវាល្បាតរបស់តៃវ៉ាន់ នៅជិតទូកនេសាទរបស់ពួកគេ ជនរងគ្រោះជឿជាក់ថា ជានាវាដើរល្បាតរបស់ប៉ូលីស ពីព្រោះមានដាក់ទង់ជាតិតៃវ៉ាន់។ កម្មករនេសាទផ្សេងទៀតបាននិយាយថា នាវាល្បាតនោះតែងតែមកជិតទូកនេសាទរបស់ពួកគេ។

## ការរត់គេចខ្លួន

ទូកបានចតនៅទីក្រុងដាការ ប្រទេសសេណេហ្គាល់ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ដោយសារសមាជិកនេសាទត្រូវការជួសជុល និងលាបថ្នាំទូក។ ជនរងគ្រោះបានឆក់យកឱកាសនេះ ទូរស័ព្ទមកបងប្រុសរបស់គាត់នៅភ្នំពេញ និងពន្យល់ពីស្ថានភាពរបស់គាត់។ បងប្រុសរបស់គាត់បានឲ្យលេខទូរស័ព្ទរបស់អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ (LSCW) ទៅគាត់ ហើយជនរងគ្រោះបានទូរស័ព្ទមកអង្គការនេះដើម្បីសុំជំនួយ។

ជនរងគ្រោះបានសុំមេក្រុមទូកម្តងទៀត ឲ្យបញ្ជូនពួកគេមកប្រទេសកម្ពុជាវិញ ប៉ុន្តែមេក្រុមទូកបានបដិសេធទៀត។ ក្នុងពេលនោះ អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ បានជូនដំណឹងទៅ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ នៅកម្ពុជាពីស្ថានភាពរបស់ជនរងគ្រោះហើយអង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅកម្ពុជា បានទាក់ទងទៅអង្គការ អន្តរជាតិទេសន្តរប្រវេសន៍នៅប្រទេសសេណេហ្គាល់ដើម្បីជួយអន្តរាគមន៍។

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ជំនួយការរបស់ក្រុមហ៊ុន Giant Ocean បានឮពីការសុំធ្វើមាតុភូមិនិវត្តរបស់ជនរងគ្រោះ។ ប៉ុន្តែគេបានបដិសេធមិនបញ្ជូនពួកគេមកកម្ពុជាវិញទេ ដោយចោទថាពួកគេត្រូវតែធ្វើការឲ្យបានបីឆ្នាំតាមកិច្ចសន្យា។

ប៉ូលីសសេណេហ្គាល់ បាននាំជនរងគ្រោះទៅការិយាល័យអង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅប្រទេសសេណេហ្គាល់ ដើម្បីសួរចម្លើយ។ នៅការិយាល័យអង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅប្រទេសសេណេហ្គាល់ ជនរងគ្រោះបានសម្ភាសជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅកម្ពុជា តាមរយៈស្កាយ (Skype)។ បន្ទាប់ពីសម្ភាសហើយ អង្គការអន្តរជាតិទេសន្តរប្រវេសន៍នៅប្រទេសសេណេហ្គាល់ បានបញ្ជូនពួកគេទៅប៉ូលីសសេណេហ្គាល់វិញ ហើយប៉ុន្មានថ្ងៃក្រោយមក ប៉ូលីសបានបញ្ជូនពួកគេទៅទូកនេសាទវិញ ដោយប៉ូលីសយល់ថាពួកគេមិនមែនជាជនរងគ្រោះនៃការជួញដូរមនុស្ស ហើយពុំមានអន្តរាគមន៍ពីរាជរដ្ឋាភិបាលកម្ពុជាទេ ជាពិសេសក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយអង្គការអន្តរជាតិទេសន្តរប្រវេសន៍មិនអាចជួយពួកគេបាន[11]។

បន្ទាប់ពីមេក្រុមទូក និងជំនួយការភ្នាក់ងារជ្រើសរើសពលករដឹងថា ជនរងគ្រោះប្តឹងទៅអង្គការអន្តរជាតិទេសន្តរប្រវេសន៍ និងអង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ ពួកគេបានឲ្យជនរងគ្រោះសរសេរ

សំបុត្រទៅក្រុមហ៊ុនតៃវ៉ាន់ ដើម្បីសុំការដោះលែង។ មេក្រុមទូកបានប្រាប់ជនរងគ្រោះថា គេនឹងអនុញ្ញាតិឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែថ្លៃសំបុត្រយន្តហោះត្រូវកាត់យកពីប្រាក់ខែរបស់ជនរងគ្រោះ។

មេក្រុមទូកបានបញ្ជាក់បន្ថែមថា ទោះបីជនរងគ្រោះ៤នាក់ត្រូវឲ្យវិលត្រឡប់មកកម្ពុជាវិញក្តី ក៏បុរស ២នាក់ទៀត ត្រូវតែនៅធ្វើការលើទូកដដែល ពីព្រោះពួកគេមិនទាន់រកប្រាក់បានគ្រប់គ្រាន់ដើម្បីទិញសំបុត្រយន្តហោះមកកម្ពុជាវិញទេ។

ជនរងគ្រោះបានទទួលប្រាក់ ៥០០ ដុល្លារអាមេរិក និងសំបុត្រយន្តហោះត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែភ្នាក់ងារជ្រើសរើសពលករបានប្រាប់ពួកគេថា ពួកគេមិនអាចទទួលប្រាក់នៅសល់ ដែលពួកគេរកបានក្នុងរយៈពេលធ្វើការ ២០ខែ នេះបានទេ ។

## ការធ្វើមាតុភូមិនិវត្ត និងការជួយឧបត្ថម្ភបន្ត

នៅថ្ងៃដែលពួកគេវិលត្រឡប់មកវិញ បុរសជនជាតិអាហ្វ្រិកបានបើកឡានជូន ជនរងគ្រោះទៅព្រលានយន្តហោះ។ ពួកគេបានឆ្លងកាត់ទីក្រុងបាងកក ហើយមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ដោយមានការអបអរសាទរពីញាតិសន្តាន។ ពួកគេបានមកជួប អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារដើម្បីសម្ភាស នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២។

អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ បានផ្តល់សេវាផ្នែកច្បាប់ និងការពិគ្រោះយោបល់ដល់ជនរងគ្រោះ ហើយជនរងគ្រោះក៏បានសម្រេចចិត្តប្តឹងក្រុមហ៊ុន Giant Ocean ។ អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ បានជួយផ្តល់មេធាវីដល់ជនរងគ្រោះដោយមិនគិត

---

[11] យោងទៅតាមជនរងគ្រោះនិងបុគ្គលិកអង្គការអន្តោប្រវេសន៍អន្តរជាតិ នៅភ្នំពេញ

កម្រៃ ដើម្បីដំណើរការប្ដឹងទៅតុលាការ។ មេធាវីក៏បានជូនគាត់ទៅនាយកដ្ឋានយុត្តិធម៌ និងប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃដើម្បីសម្ភាសន៍ និងដាក់ពាក្យបណ្ដឹង។ បណ្ដឹងរបស់គាត់បានបញ្ជូនទៅតុលាការរាជធានីភ្នំពេញ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២។

ម្យ៉ាងវិញទៀត អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ បានបញ្ជូនជនរងគ្រោះទៅអង្គការដៃគូរដែលអង្គការនោះឈ្មោះថាអង្គការសហប្រតិបត្តិការស្ត្រីខ្មែរដើម្បីអភិវឌ្ឍន៍ដើម្បីឲ្យចូលរៀនជំនាញវិជ្ជាជីវៈ។ អង្គការនេះបានបង្រៀនគាត់ពីរបៀបចិញ្ចឹមមាន់នៅសាលាកសិកម្មជាតិព្រែកលាប។

## ប្រទេសអាហ្វ្រិកខាងត្បូង (៨ករណី)

## ប្រទេសអាហ្វ្រិកខាងត្បូង ករណីទី១

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ១នាក់ មកពីខេត្តកំពង់ចាម |
| ទិសដៅ | ប្រទេសអាហ្វ្រិកខាងត្បូង |
| កាលបរិច្ឆេទនៃការចេញដំណើរ | ០៩ កញ្ញា ២០១០ |
| កាលបរិច្ឆេទនៃការវិលត្រឡប់ | ២១ ខែកក្កដា ឆ្នាំ ២០១២ |
| ប្រាក់ខែដែលសន្យាឲ្យ | ២០០ ដុល្លាមួយខែ |
| ប្រាក់ខែទទួលបានសរុប | គ្មាន ទទួលបានតែសំបុត្រយន្តហោះមកផ្ទះវិញ |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរមនុស្សឆ្លងដែនដើម្បីកេងប្រវ័ញ្ចពលកម្ម<br>- ធ្វើការ ១៨ ទៅ ២០ ម៉ោងក្នុងមួយថ្ងៃ<br>- គ្មានទទួលប្រាក់ខែ<br>- រំលោភបំពានដល់រាងកាយ<br>- ខ្វះអាហារ<br>- គំរាមកំហែងដល់ស្លាប់ |
| ភ្នាក់ងារជ្រើសរើស | ក្រុមហ៊ុន Giant Ocean International Fishery Co.,Ltd. |
| កាលបរិច្ឆេទនៃការបំពេញពាក្យបណ្ដឹង | ២១ ខែកក្កដា ឆ្នាំ២០១២ |
| សំណងដែលទាមទារ | ៦៩០០ដុល្លារអាមេរិក |

| | |
|---|---|
| សេវាគាំទ្រដែលបានផ្តល់ដោយគម្រោង CTIP II | - សេវាផ្នែកច្បាប់និងពិគ្រោះយោបល់<br>- ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីធ្វើជាតំណាងជនរងគ្រោះនៅតុលាការ<br>- ជួយជនរងគ្រោះទៅសម្ភាសន៍ និងដាក់ពាក្យបណ្តឹងទៅប៉ូលីសនាយកដ្ឋានយុត្តិធម៌និង ប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ |

ជនរងគ្រោះបានឮការប្រកាសតាមវិទ្យុនៅខេត្តកំពង់ចាមពីក្រុមហ៊ុន Giant Ocean ថាផ្តល់ការងារធ្វើនៅប្រទេសជប៉ុន។ ដោយមានការចាប់អារម្មណ៍ គាត់បានធ្វើដំណើរទៅសម្ភាសនៅការិយាល័យភ្នាក់ងារជ្រើសរើសពលករនៅភ្នំពេញ។ ភ្នាក់ងារជ្រើសរើសពលករ បានរៀបចំឯកសារធ្វើដំណើររបស់គាត់ ហើយគាត់បានចេញដំណើរទៅប្រទេសផ្សេង (គាត់អត់ដឹងថាប្រទេសណាមួយដែលគាត់ត្រូវទៅនោះទេ)។

ពេលទៅដល់ប្រទេសគោលដៅ គាត់បានដឹងថា គាត់មិនបាននៅក្នុងប្រទេសជប៉ុនទេ។ គាត់នៅប្រទេសអាហ្វ្រិក ប៉ុន្តែគាត់មិនដឹងថាប្រទេសណាមួយនោះទេ ។ នៅព្រលានយន្តហោះ មានគេមកទទួលគាត់ ហើយយកគាត់ទៅធ្វើការងារនេសាទ តាមកប៉ាល់។

នៅពេលនោះ កប៉ាល់បានចតនៅកំពង់ផែ ប៉ុន្តែជនរងគ្រោះនៅតែធ្វើការ៨ម៉ោងដដែលក្នុងមួយថ្ងៃ។ គាត់បានរាយការណ៍ថា ប្រធានក្រុមទូកបានធ្វើទុក្ខទោសគាត់ និងបង្អត់អាហារគាត់។ ប្រធានក្រុមទូកបានវាយធ្វើបាបគាត់ បង្ខំឲ្យធ្វើការធ្ងន់ និងជូនកាលគំរាមសម្លាប់គាត់។ ការគំរាមកំហែងឥតមេត្តានេះ ធ្វើឲ្យគាត់សម្រេចចិត្តរត់គេចជាបន្ទាន់។

នៅពេលចូលឆ្នាំចិន គាត់បានទទួលប្រាក់បន្តិចបន្តួចសម្រាប់ចំណាយផ្សេងៗនៅកំពង់ផែ និងសម្រាប់ចំណាយថ្លៃទូរស័ព្ទទាក់ទងមកគ្រួសារ ដោយសង្ឃឹមថាក្រុមគ្រួសារអាចជួយគាត់រត់គេចពីស្ថានភាពលំបាកនេះបាន។ ក្រោយមកគ្រួសារគាត់បានទាក់ទងអង្គការអន្តរជាតិទេសន្តរប្រវេសន៍។ នៅទីបញ្ចប់ជនរងគ្រោះ បានធ្វើមាតុភូមិនិវត្តមកប្រទេសកម្ពុជាវិញ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១២។

## ប្រទេសអាហ្វ្រិកខាងត្បូង ករណីទី២

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ៣នាក់ មកពីរាជធានីភ្នំពេញ |
| ទិសដៅ | ប្រទេសអាហ្វ្រិកខាងត្បូង |
| កាលបរិច្ឆេទនៃការចេញដំណើរ | ខែវិច្ឆិកា ឆ្នាំ២០១១ |
| កាលបរិច្ឆេទនៃការវិលត្រឡប់ | ខែមីនា ឆ្នាំ២០១២ |
| ប្រាក់ខែដែលសន្យាឲ្យ | ១៥0 ដុល្លារអាមេរិក |
| ប្រាក់ខែទទួលបានសរុប | ២00 ដុល្លារអាមេរិក |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរមនុស្សឆ្លងដែនដើម្បីកេងប្រវ័ញ្ចពលកម្ម<br>- គ្មានទទួលប្រាក់ខែ<br>- ធ្វើការ១៨ម៉ោងក្នុងមួយថ្ងៃ<br>- រំលោភបំពានដល់រាងកាយ<br>- ការរើសអើង<br>- ខ្វះអាហារ |
| ភ្នាក់ងារជ្រើសរើស | ក្រុមហ៊ុនGiant Ocean International Fishery Co., Ltd. |
| កាលបរិច្ឆេទនៃការបំពេញពាក្យបណ្តឹង | ២១ មីនា២០១២ |
| សំណាងដែលទាមទារ | ៦000ដុល្លា |

| | |
|---|---|
| សេវាគាំទ្រដែលបានផ្តល់ដោយគម្រោង CTIP II | -សេវាផ្នែកច្បាប់និងពិគ្រោះយោបល់<br>- ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីនាំជនរងគ្រោះទៅតុលាការ<br>-ជួយជនរងគ្រោះទៅសម្ភាសន៍ និងដាក់ពាក្យបណ្តឹងទៅប៉ូលីស<br>នាយកដ្ឋានយុត្តិធម៌និងប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ |

ជនរងគ្រោះ ២នាក់ ជ្រើសរើសដោយក្រុមហ៊ុន Giant Ocean ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ជនរងគ្រោះម្នាក់ទៀតដែលបានរៀបរាប់ក្នុងករណីនេះដែរ បានរាយការណ៍ថាគាត់បានចុះឈ្មោះជាមួយភ្នាក់ងារជ្រើសរើសពលករដូចគ្នានៅខ័ណ្ឌទួលគោក។ មុនពេលគាត់ចេញដំណើរ គាត់ត្រូវបានបង្រៀនមួយសប្តាហ៍ ពីជំនាញនេសាទ។

ភ្នាក់ងារជ្រើសរើសពលករ ទទួលបង់ថ្លៃឯកសាររបស់គាត់ហើយក្រោយមកកាត់ពីប្រាក់ខែរបស់គាត់វិញ ចំនួន៩៨០ ដុល្លារអាមេរិក។ ក្រុមហ៊ុននេះបានសន្យាផ្តល់ប្រាក់ខែ ១៥០ ដុល្លារអាមេរិក ក្នុងមួយខែដើម្បីធ្វើការងារនេសាទនៅប្រទេសអាហ្វ្រិកខាងត្បូង។ ផ្ទុយពីកិច្ចសន្យារបស់ក្រុមហ៊ុន Giant Ocean ជនរងគ្រោះទាំងបីនាក់បានរាយការណ៍ថាពួកគាត់ត្រូវបានប្រាប់ជាចំហថាទៅធ្វើការនៅប្រទេស អាហ្វ្រិកខាងត្បូង។ ភ្នាក់ងារក្រុមហ៊ុនបានប្រាប់ពួកគាត់ថា គ្រួសាររបស់ពួកគេ នឹងទទួលប្រាក់ដោយផ្ទាល់ពីក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា។

ឯកសារដែលប្រមូលពីជនរងគ្រោះ ដោយភ្នាក់ងារគាំទ្របានបញ្ជាក់ថា ជនរងគ្រោះបានធ្វើដំណើរឆ្លងកាត់ទីក្រុងបាងកក ឌុយបៃ (Dubai) ឌូបាន(Durban) និងក្រុងខេបថោន (Cape Town) នៅតាម

ផ្លូវសំដៅទៅកប៉ាល់នេសាទ។ នៅពេលពួកគេដល់ព្រលានយន្តហោះ មានជនជាតិតៃវ៉ាន់មកជួបពួកគេ នឹងនាំទៅទូកនេសាទ ដែលមានឈ្មោះ យូតៀន (Yu Tien) ។ នៅលើទូកពួកគេត្រូវបង្ខំឲ្យធ្វើការ ១៨ម៉ោងក្នុងមួយថ្ងៃ ដោយអូសទាញសំណាញ់ និងតម្រៀបត្រីតាមប្រភេទ។ ចំណែកឯអាហារវិញ សមាជិកយានិក ទទួលអាហារ ៣ពេលក្នុងមួយថ្ងៃ ប៉ុន្តែពួកគេសឹងតែគ្មានពេលហូបបាយ ព្រោះថាពេលឈប់សម្រាកហូបបាយមានរយៈពេលតែ១៥នាទីប៉ុណ្ណោះ។ ជនរងគ្រោះបានរាយការណ៍ ថាអ្នកនេសាទទាំងអស់ត្រូវបានធ្វើទុក្ខទោសផ្នែករាងកាយ ជាពិសេសកម្មករខ្មែរ ដោយសារពួកគេមិនយល់ពីបទបញ្ជារបស់នាយនាវិក។ គ្មានជនរងគ្រោះណាដែលមិនត្រូវបានស្តីបន្ទោសទេ។ មានបុរសនេសាទ ៤០នាក់មកពី ៥ សញ្ជាតិផ្សេងៗគ្នា ដូចជា កម្ពុជា វៀតណាម ហ្វីលីពីន ឥណ្ឌូនេស៊ី ភូមា ដែលធ្វើការ ក្នុងលក្ខខណ្ឌដូចគ្នានៅលើទូក។

បុរសម្នាក់ រាយការណ៍ថា ភ្នាក់ងារជ្រើសរើសពលករក្នុងប្រទេសគោលដៅ បានចំណាយ ៦០០ ដុល្លារអាមេរិក សំរាប់កម្មករខ្មែរម្នាក់ (កម្មករវៀតណាមប្រហែល ៨០០ ដុល្លារអាមេរិក) ប៉ុន្តែ ភ្នាក់ងារជ្រើសរើសក្នុងស្រុក បានទទួលតែ១៥០ ដុល្លារអាមេរិកទេ។ ចំនួននេះ ជាកម្មវត្ថុនៃការកាត់យកវិញ ដូចដែលបានធ្វើជាមួយអ្នកនេសាទមុនៗ ។

គ្រួសារជនរងគ្រោះរាយការណ៍ថា ពួកគេបានទទួលប្រាក់តែ ២ ខែប៉ុណ្ណោះ សរុបចំនួន ២០០ ដុល្លារអាមេរិក តាមរយៈជនរងគ្រោះ ដែលបានធ្វើការនៅលើកប៉ាល់នេសាទប្រហែលជា ៦ខែ។ ក្រុមហ៊ុន Giant Ocean បានធ្វើមាតុភូមិនិវត្តពួកគេ មុនពេលចប់កិច្ចសន្យា ក្នុងខែមីនា ឆ្នាំ ២០១២ ដោយមានជនរងគ្រោះម្នាក់បានធ្វើពុតថាគាត់មានជម្ងឺធ្ងន់ធ្ងរ ។

## ប្រទេសអាហ្រ្វិកខាងត្បូង ករណីទី៣

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ ៣នាក់ មកពីខេត្តតាកែវ |
| ទិសដៅ | ប្រទេសអាហ្រ្វិក |
| កាលបរិច្ឆេទនៃការចេញដំណើរ | ២២ តុលា ឆ្នាំ២០១១ |
| កាលបរិច្ឆេទនៃការវិលត្រឡប់ | ៣០ កក្កដា ឆ្នាំ២០១២ |
| ប្រាក់ខែដែលសន្យាឲ្យ | ២០០ ដុល្លារអាមេរិក ក្នុងមួយខែ |
| ប្រាក់ខែទទួលបានសរុប | ១៩០ ដុល្លារអាមេរិក |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរ និងកេងប្រវ័ញ្ចពលកម្ម<br>- ធ្វើការ ២០ ម៉ោងក្នុងមួយថ្ងៃ<br>- ខ្វះអាហារ<br>- រំលោភបំពានដល់រាងកាយ<br>- មិនផ្តល់ប្រាក់ខែឲ្យ |
| ភ្នាក់ងារជ្រើសរើស | Giant Ocean International Fishery Co., Ltd. |
| កាលបរិច្ឆេទនៃការបំពេញពាក្យបណ្តឹង | ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ |
| សំណងដែលទាមទារ | ៦០០ ដុល្លារអាមេរិក |
| សេវាគាំទ្រដែលបានផ្តល់ដោយគម្រោង CTIP II | -សេវាផ្នែកច្បាប់និងពិគ្រោះយោបល់<br>-ផ្តល់មេធាវីដោយមិនយកកម្រៃ ដើម្បីនាំជនរងគ្រោះទៅតុលាការ<br>- ជួយជនរងគ្រោះទៅសម្ភាសសន៍ និងដាក់ពាក្យបណ្តឹងទៅប៉ូលីស នាយកដ្ឋានយុត្តិធម៌និងប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ |

ជនរងគ្រោះ ៥នាក់ ត្រូវបានជ្រើសរើសដោយក្រុមហ៊ុន Giant Ocean នៅខែតុលា ឆ្នាំ២០១១។ ពួកគេបានចុះហត្ថលេខាលើឯកសារនៃកិច្ចសន្យាដោយភាគីតែម្ខាង ដោយសន្យាថានាឲ្យបុរសទាំងនោះបានធ្វើការងារ លើកប៉ាល់នេសាទនៅប្រទេសជប៉ុន ហើយទទួលប្រាក់បន្ថែមសម្រាប់ថ្លៃបារីចំនួន ២០ ដុល្លាអាមេរិកក្នុងមួយថ្ងៃ ។ ជនរងគ្រោះបានទទួលប្រាក់ ៩០ ដុល្លាអាមេរិក ដើម្បីទិញសំលៀកបំពាក់ និងត្រៀមចេញដំណើរ។ ភ្នាក់ងារជ្រើសរើសពលករបានពន្យល់ថាចំនួននេះនឹងត្រូវកាត់យកវិញពីប្រាក់ខែដំបូងរបស់ពួកគេ។

ទោះបីជាជនរងគ្រោះទាំង៥នាក់ ត្រូវបានប្រាប់ឲ្យទៅធ្វើការនៅប្រទេសជប៉ុនក៏ដោយ ពួកគេត្រូវបាននាំទៅប្រទេសផ្សេងទៅវិញ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១១ ពួកគេបានទៅដល់ទីក្រុង ខែប ថោន (Cape Town) ប្រទេសអាហ្វ្រិកខាងត្បូង បន្ទាប់ពីឆ្លងកាត់ទីក្រុងបាងកក និងឌូហា។ នៅពេលទៅដល់ព្រលានយន្តហោះ ជនជាតិតៃវ៉ាន់ដែលគេមិនស្គាល់អត្តសញ្ញាណ បានមកទទួលពួកគេ នឹងនាំទៅកំពង់ផែនេសាទ។

ទូកនេសាទ គឺគ្រប់គ្រងដោយបុរសជនជាតិតៃវ៉ាន់ ៣នាក់។ បន្ទាប់ពីជួសជុលទូកអស់រយៈពេលមួយខែ ទូកបានចេញដំណើរទៅសមុទ្រ។

ទូកបានស្នាក់នៅលើសមុទ្រអស់រយៈពេល ១០ខែ ដោយផ្ទេរផលិតផលនេសាទ ដែលចាប់បានទៅកប៉ាល់នេសាទផ្សេងៗទៀត។ ការធ្វើបែបនេះ ដើម្បីកុំឲ្យ សមាជិកនេសាទឃើញដីគោក រត់គេច ហើយតែងតែ ផ្ទេរពីទូក ទៅកប៉ាល់អ្នកទោសផ្សេងទៀត។ ជាធម្មតា អ្នកនេសាទធ្វើការ ២០ម៉ោង។ ពាក់ព័ន្ធនិងអាហារ ពួកគេហូបតែបាយ ឬមី ជូនកាល២ដង

ក្នុងមួយថ្ងៃ និងជួនកាលមិនបានហូបអ្វីទាំងអស់។ ជនរងគ្រោះបានរាយការណ៍ថា ជួនកាលពួកគេ បង្ខំហូបនុយត្រី ដើម្បីជៀសវាងដាច់ពោះស្លាប់។

ពួកគេតែងតែត្រូវបានទះ ឬវាយធ្វើបាប ប្រសិនបើពួកគេមិនធ្វើការឲ្យរហ័ស ឬអស់ពីសមត្ថភាពទេនោះ។ ពួកគេបន្ថែមថាពួកគេធ្លាក់ខ្លួនឈឺជាច្រើនថ្ងៃ ហើយមិនត្រូវឲ្យឈប់សំរាក ឬឲ្យលេបថ្នាំតាមតម្រូវការឡើយ។

បន្ទាប់ពីរស់នៅលើសមុទ្រអស់រយៈពេល ១០ខែ ទូកនេសាទបានត្រឡប់មកចតនៅផែ នៃទីក្រុង ខេបថោន ប្រទេសអាហ្វ្រិកខាងត្បូង ដោយសារប្រព័ន្ធអុកស៊ីតកម្មដំណើរការមិនត្រឹមត្រូវ។ នៅពេលចុះពីទូក ប្រធានក្រុមទូក បានឲ្យប្រាក់ទៅជនរងគ្រោះចំនួន ១០០ ដុល្លារអាមេរិក ដើម្បីស្នាក់នៅទីក្រុង ក្នុងពេលដែលប្រព័ន្ធអុកស៊ីតកម្មត្រូវការជួសជុល។ គេកត់សម្គាល់ថា ប្រធានក្រុមទូក បានដកហូតយក លិខិតឆ្លងដែន ពីជនរងគ្រោះទាំងអស់ ដើម្បីកុំឲ្យពួកគេរត់គេចខ្លួន។ ជនរងគ្រោះបានទាក់ទងមកក្រុមគ្រួសារ ដែលរស់នៅប្រទេសកម្ពុជា ដែលជាអ្នកជូនដំណឹងទៅអង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ ។ ដោយមានការសម្របសម្រួលពីមន្ត្រីជាន់ខ្ពស់ផ្នែកអន្តោប្រវេសន៍ក្នុងទីក្រុងហាប្ឫរ ជនរងគ្រោះបានធ្វើមាតុភូមិនិវត្តវិញ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ដែលនិយោជកទទួលខុសត្រូវរាល់ការចំណាយទាំងអស់។ ភ្នាក់ងារដែលគេមិនស្គាល់ជាជនជាតិចិន ឬតៃវ៉ាន់ លោក គ្រីសតូបហ្វឺ ឌីង(Christopher Ding) មកពីក្រុមហ៊ុនពាណិជ្ជកម្មតាមសមុទ្រ ជាអ្នករៀបចំសំបុត្រឲ្យត្រឡប់មកវិញ។ ជនរកគ្រោះទទួលបានប្រាក់តែ ១៩០ ដុល្លារអាមេរិក ប៉ុណ្ណោះក្នុងរយៈពេល៩ខែ ដែលទៅធ្វើការ។

## ប្រទេសអាហ្វ្រិកខាងត្បូង ករណីទី៤

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ ១នាក់ មកពីខេត្តកំពត |
| ទិសដៅ | ប្រទេសអាហ្វ្រិក |
| ថ្ងៃចេញដំណើរ | ខែកញ្ញា ឆ្នាំ២០១១ |
| ថ្ងៃវិលត្រឡប់ | ខែធ្នូ ឆ្នាំ២០១១ |
| ប្រាក់ខែដែលសន្យាផ្តល់ឲ្យ | ២០០ ដុល្លារអាមេរិក |
| ប្រាក់ខែទទួលបានសរុប | គ្មាន |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរ និងកេងប្រវ័ញ្ចពលកម្ម<br>- ធ្វើការ ២០ ម៉ោងក្នុងមួយថ្ងៃ<br>- មិនផ្តល់ប្រាក់ខែឲ្យ |
| ភ្នាក់ងារជ្រើសរើស | Giant Ocean International Fishery Co., Ltd or Phoenix International Co., Ltd |
| ថ្ងៃខែបំពេញពាក្យបណ្តឹង | ០៩ ខែមករា ឆ្នាំ២០១២ |
| សំណងដែលទាមទារ | ៥៥០០ ដុល្លារអាមេរិក |
| សេវាដែលទទួលការគាំទ្រពី CTIP II | -សេវាផ្នែកច្បាប់ និងពិគ្រោះយោបល់<br>-ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីតំណាងឲ្យជនរងគ្រោះនៅពេលដំណើរការក្តី<br>-ជយ័ជនរងគ្រោះកងការរៀបចំកិច្ចសម្ភាសន៍និងដាក់ពាក្យបណ្តឹងទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារ អានីតិជននៃក្រសួងមហាផ្ទៃ |

ជនរងគ្រោះ ១នាក់មកពីខេត្តកំពត ដែលជ្រើសរើសដោយក្រុមហ៊ុន Giant Ocean International Fishery Co., Ltd or Phoenix International Co., Ltd ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន។ ការទំនាក់ទំនងរវាងក្រុមហ៊ុនទាំងពីរនេះមិនច្បាស់លាស់។ មិនដូចជាក្រុមហ៊ុន Giant Ocean International Fishery Co., Ltd ទេ ក្រុមហ៊ុន Phoenix International Co., Ltd មិនត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈជនរងគ្រោះ លេខទូរស័ព្ទទំនាក់ទំនងក្នុងប្រទេសកម្ពុជា មានក្នុងលិខិតរបស់ក្រុមហ៊ុន Giant Ocean International Fishery Co., Ltd ដែលបានផ្សាយពាណិជ្ជកម្ម។

ទោះបីយ៉ាងណា គាត់មិនបានទៅដល់ប្រទេសជប៉ុនទេ ហើយទីបញ្ចប់គាត់ទៅធ្វើការនៅលើទូក ដែលមានឈ្មោះ យូស៊ីងសាង (Yu Sing Sang) ដែលមានដាក់ទង់ជាតិតៃវ៉ាន់ និងអាហ្វ្រិកខាងត្បូង។

គាត់បានធ្វើការនៅកំពង់ផែ សាវ៉ានូតូ (Savanoto) ហើយវាជាកំពង់ផែដ៏សំខាន់នៃតំបន់ សាលដានហា (Saldanha) ជិតទីក្រុងខែបនៃប្រទេសអាហ្វ្រិកខាងត្បូង។ ជនរងគ្រោះរាយការណ៍ថា គាត់បានឃើញជនជាតិកម្ពុជាជាច្រើនធ្វើការនៅកំពង់ផែនេះដែរ។ បុគ្គលិក Giant Ocean International Fishery Co., Ltd ដែលជាជនជាតិកម្ពុជា បានជួបគាត់នៅកំពង់ផែនោះដែរ។

ជនរងគ្រោះបានរាយការណ៍បន្ថែមថា មានបុរស៤នាក់ផ្សេងទៀតបានវិលត្រឡប់មកកម្ពុជាវិញជាមួយគាត់ ហើយថ្លៃធ្វើដំណើរត្រឡប់មកវិញចេញដោយភ្នាក់ងារជ្រើសរើសពលករ Giant Ocean International Fishery Co., Ltd or Phoenix International Co., Ltd ឬមេការទូក។ បុរសទាំងនោះធ្វើការនៅលើទូកច្រើនជាង៣ខែ។ បន្ទាប់ពីការវិលត្រឡប់

មកប្រទេសកម្ពុជាវិញ វាហាក់បីដូចជា អ្នកជ្រើសរើសជនរងគ្រោះទទួល រងគ្រោះពីភ្នាក់ងាររបស់គាត់ផ្ទាល់។ ការពិត កូនប្រុស២ នាក់ និងកូនប្រសារប្រុស ១នាក់របស់គាត់ កំពុងតែបាត់ខ្លួន។ ក្រុមគ្រួសារដែលរស់នៅក្នុងតំបន់នោះ បានរាយការណ៍ថា ពុំមានបុរសរស់នៅក្នុងគ្រួសារទេ ដោយសារពួកគេទៅធ្វើការងារនេសាទតាមកប៉ាល់អស់។

## ប្រទេសអាហ្វ្រិកខាងត្បូង ករណីទី៥

| | |
|---|---|
| ចំនួនជនរងគ្រោះ និងស្រុកកំណើត | ជនរងគ្រោះ ១នាក់ មកពីខេត្តកំពត |
| ទិសដៅ | ប្រទេសអាហ្វ្រិកខាងត្បូង |
| ថ្ងៃចេញដំណើរ | ០៧ ខែតុលា ឆ្នាំ២០១១ |
| ថ្ងៃវិលត្រឡប់ | ២៣ ធ្នូ ឆ្នាំ២០១១ |
| ប្រាក់ខែដែលសន្យាផ្តល់ឲ្យ | ២០០ ដុល្លារអាមេរិក ក្នុងមួយខែ និងប្រាក់បន្ថែម ២០ ដុល្លារអាមេរិក |
| ប្រាក់ខែទទួលបានសរុប | គ្មាន |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរ និងកេងប្រវ័ញ្ចពលកម្ម<br>- មិនផ្តល់ប្រាក់ខែឲ្យ<br>- ខ្វះខាតអាហារ<br>- ធ្វើការ ១៥ ម៉ោងក្នុងមួយថ្ងៃ |
| ភ្នាក់ងារជ្រើសរើស | Phoenix International Co., Ltd |
| ថ្ងៃខែបំពេញពាក្យបណ្តឹង | ០៩ ខែមករា ឆ្នាំ ២០១២ |
| សំណងដែលទាមទារ | ៦០០០ដុល្លារអាមេរិក |
| សេវាដែលទទួលការគាំទ្រ ពីCTIP II | -សេវាផ្នែកច្បាប់ និងពិគ្រោះយោបល់<br>-ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីតំណាងឲ្យជនរងគ្រោះនៅពេលដំណើរការក្តី |

| | |
|---|---|
| | -ជួយជនរងគ្រោះក្នុងការរៀបចំកិច្ចសម្ភាសន៍ និងដាក់ពាក្យបណ្តឹងទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអានីតិជននៃក្រសួងមហាផ្ទៃ |

ជនរងគ្រោះក្នុងករណីនេះ គឺត្រូវបានជ្រើសរើសដោយមេខ្យល់ជនជាតិខ្មែរ ក្នុងប្រទេសកម្ពុជាដែលលួងលោមពួកគេ ដោយសន្យាផ្តល់នូវឱកាសការងារដែលមានប្រាក់ខែខ្ពស់ នៅខែកញ្ញា ឆ្នាំ២០១១។ មេខ្យល់បានសន្យាថានឹងផ្តល់ការងារធ្វើនៅប្រទេសជប៉ុនរយៈពេល២៥ខែ ដោយទទួលប្រាក់ខែ ២០០ដុល្លារអាមេរិក ក្នុងមួយខែ និងប្រាក់បន្ថែម ២០ដុល្លារអាមេរិក។ ជនរងគ្រោះបាននិយាយថាគាត់ជឿ ទុកចិត្តលើមេខ្យល់នោះ ដោយគាត់ស្គាល់មេខ្យល់នោះជាអ្នកជិតខាង ដែលមានអាយុ ៤៥ឆ្នាំ ។ ជនរងគ្រោះមិនមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរទេ ក្រៅតែពីកិច្ចសន្យាផ្ទាល់មាត់ប៉ុណ្ណោះ។

ជនរងគ្រោះបាននិយាយថា មេខ្យល់នេះបានឲ្យប្រាក់គាត់ ចំនួន ៦០ដុល្លារអាមេរិក ជាប្រាក់បើក ឲ្យមុន ដើម្បីបញ្ចុះបញ្ចូលគាត់ឲ្យទទួលយកការងារនោះ។

ជនរងគ្រោះ និងមនុស្ស៧នាក់ផ្សេងទៀត បានទទួលធ្វើការងារនោះ ហើយបានធ្វើដំណើរទៅការិយាល័យក្រុមហ៊ុន Phoenix International Co., Ltd នៅភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១។ ការិយាល័យរបស់ក្រុមហ៊ុន គឺមានទីតាំងនៅជិតផ្សារដីហុយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ នៅពេលជនរងគ្រោះទៅដល់ បុគ្គលិកជ្រើសរើសក្រុមហ៊ុន បាននាំពួកគេចូលទៅក្នុងការិយាល័យ។ ទ្វារការិយាល័យក្រុមហ៊ុនចាក់សោគ្រប់ពេល។ ក្នុងកំឡុងពេលជនរងគ្រោះ

ស្នាក់នៅបុគ្គលិកក្រុមហ៊ុន បង្ហាញរូបថតការងារ ដែលពួកគេត្រូវធ្វើនៅពេលអនាគត និងរូបថតទូក ដែលធ្វើការនៅទីនោះ។ ជនរងគ្រោះស្នាក់នៅក្នុងការិយាល័យនោះរយៈពេល ៣ថ្ងៃ។ ក្នុងកំឡុងពេលនោះ គាត់នៅតែជឿជាក់ថា គាត់ទៅធ្វើការនៅប្រទេសជប៉ុន។

នៅល្ងាចថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ មានបុរស ២នាក់ ដែលជាបុគ្គលិកភ្នាក់ងារជ្រើសរើសរបស់ក្រុមហ៊ុន គឺប្រហែលជា លោក ថយ (Toi) និងលោកឆាយ (Chhai) បាននាំជនរងគ្រោះទៅព្រលានយន្តហោះ។ នៅព្រលានយន្តហោះ ពួកគេបានឲ្យលិខិតឆ្លងដែន និងសៀវភៅកំណត់ត្រាកម្មករនេសាទ[12] (Seaman's Book)។ គាត់ចាកចេញពីកម្ពុជានៅពេលយប់ ហើយឆ្លងកាត់ទីក្រុងបាងកក និងទីក្រុងផ្សេងទៀត មុនទៅដល់កន្លែងដែលមិនមែនគោលដៅ គឺប្រទេសអាហ្វ្រិកខាងត្បូង។

នៅព្រលានយន្តហោះ បុរសម្នាក់ប្រហែលជាជនជាតិចិន បានសួរគាត់ថា តើគាត់ជាជនជាតិកម្ពុជាមែនទេ ។ ក្រោយពីជនរងគ្រោះឆ្លើយថា បាទ បុរសនោះបានបើករថយន្តជូនគាត់ទៅកាន់ការិយាល័យមួយដែលនៅក្បែរកំពង់ផែ។ មានមន្ត្រីម្នាក់អង្គុយក្នុងការិយាល័យទំនងជាមន្ត្រីនាវិក បានដកហូតលិខិតឆ្លងដែនរបស់គាត់ ហើយយកគាត់ទៅកាន់កប៉ាល់នេសាទ ដែលមានទីតាំងទំនងជានៅ "Savannah" (អាចជាកំពង់ផែ Saldanha) ។ កប៉ាល់នេសាទនោះមានឈ្មោះថា Zin Xiang លេខ ៦៦ និងមានអ្នកនេសាទផ្សេងទៀតចំនួន៣០នាក់នៅលើកប៉ាល់នោះ ដែលមកពីប្រទេសហ្វីលីពីន ចិន និងកម្ពុជា។ ផ្ទុយនិងច្បាប់ទូកមានដាក់ទង់ជាតិចំនួន២ ទង់ជាតិតៃវ៉ាន់នៅពីខាងមុខទូក និងទង់ជាតិប្រទេសអាហ្វ្រិកខាងត្បូងដាក់ពីក្រោយទូក។

---

12 សៀវភៅកម្មករនេសាទ គឺជាលិខិតបញ្ជាក់ដែលកត់ត្រាពីវិជ្ជាជីវៈ និងបទពិសោធន៍។ វាមិនមែនជាលិខិតឆ្លងដែន ឬទិដ្ឋាការទេ។

ជនរងគ្រោះធ្វើការនៅលើទូក ដែលចតនៅឯកំពង់ផែចំនួន ២ ខែ។ គាត់ធ្វើការតាំងពីម៉ោង៦ព្រឹករហូតដល់ម៉ោង ៨យប់ និងហូបបាយ ៣ពេលក្នុងមួយថ្ងៃ ប៉ុន្តែហាមមិនឲ្យឈប់សំរាក។ ការងាររបស់គាត់គឺ ជួសជុលសំណាញ់ និងសំអាតទូក។ ក្នុងរយៈពេល ២ខែនេះ ជនរងគ្រោះមិនដែលបានទទួលប្រាក់ខែតាមសន្យាឲ្យទេ។ដោយគាត់មិនបានទទួលតម្លៃជំងឺចិត្តពីការរំលោភបំពានពីសមាជិកនេសាទផ្សេងទៀត និងលក្ខខណ្ឌការងារលំបាក គាត់សម្រេចរត់គេចពីកន្លែងនរកលោកីយ៍នេះ។

ថ្ងៃមួយ គាត់បានរត់គេចចេញពីទូកនេសាទ ហើយដើររហូតទៅដល់ការិយាល័យភ្នាក់ងារជ្រើសរើសពលករនៅឯកំពង់ផែ។ មានសញ្ញាសរសេរជាភាសាចិនឲ្យរង់ចាំនៅខាងក្រៅ និងមានទង់ជាតិចិនតៃវ៉ាន់នៅខាងក្នុងការិយាល័យនោះ។ ហេតុនេះហើយបានជាជនរងគ្រោះជឿថាជាការិយាល័យរបស់ក្រុមហ៊ុន Phoenix International Co., Ltd ។

ជនរងគ្រោះ និងកម្មករជាជនជាតិកម្ពុជា បានជួបគ្នានៅទីនោះ និងប្រាប់ទៅបុគ្គលិកក្រុមហ៊ុនថា ពួកគាត់ចង់ត្រឡប់ទៅប្រទេសកម្ពុជាវិញ។ បុគ្គលិកក្រុមហ៊ុនមិនឆ្លើយតបនឹងការសុំរបស់ពួកគេឡើយ។ ជាចុងក្រោយ គាត់បានស្នាក់នៅឯការិយាល័យនោះ ២៥ថ្ងៃ និងទទួលបានអាហារតែតិចតួចប៉ុណ្ណោះ។ មួយសប្តាហ៍មុនគាត់មកដល់ លោកឆាយ បានមកដល់ទីនោះ ហើយឲ្យអាហារមកគាត់ និងកម្មករថ្មី ២៤នាក់ផ្សេងទៀត និងសន្យាថានឹងធ្វើមាតុភូមិនិវត្តពួកគេនិងគាត់មកប្រទេសកម្ពុជាវិញ។ លោកឆាយ បានចាកចេញប្រហែលមួយសប្តាហ៍ក្រោយមក ហើយមុនគាត់ចេញទៅ គាត់បានសុំឯកសារ ដែលមានផ្តិតមេដៃពីជនរងគ្រោះ។ ជនរងគ្រោះជឿជាក់ថាឯកសារប្រហែលជាកិច្ចសន្យា ដែលមិនអាចចាត់វិធានការណ៍ផ្លូវច្បាប់ប្រឆាំងនិងក្រុមហ៊ុន Phoenix International Co., Ltd បានទេ។ LSCW បានព្យាយាមរកឯកសារផ្សេងៗទៀត ដើម្បីដោះស្រាយបញ្ហា

ប៉ុន្តែឯកសារទាំងអស់រក្សាទុកដោយ ភ្នាក់ងារក្រុមហ៊ុន ហើយជនរងគ្រោះមិនដែលបានទទួល និងថតចំលងឯកសារណាមួយទុកឡើយ។

ជនរងគ្រោះបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែមិនអាចចងចាំអ្វីច្បាស់លាស់ ដោយសារមានជម្ងឺស្វិតរាងកាយ ដែលកើតមាននៅពេលដែលគាត់ត្រូវបានគេជួញដូរ។ គម្រោង CTIP II បានសុំជនរងគ្រោះឲ្យទៅព្យាបាលជាមួយអង្គការដៃគូរក្រៅរដ្ឋាភិបាល ប៉ុន្តម្តាយរបស់គាត់ចង់ព្យាបាលគាត់ជាមួយពេទ្យខ្មែរបុរាណវិញ។

## ប្រទេសអាហ្វ្រិកខាងត្បូង ករណីទី៦

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ ១នាក់ មកពីរាជធានីភ្នំពេញ |
| ទិសដៅ | ប្រទេសអាហ្វ្រិកខាងត្បូង |
| ថ្ងៃចេញដំណើរ | ខែតុលា ឆ្នាំ២០១១ |
| ថ្ងៃវិលត្រឡប់ | ០៨ សីហា ឆ្នាំ ២០១២ |
| ប្រាក់ខែដែលសន្យាផ្តល់ឲ្យ | ១៥០ ដុល្លារអាមេរិក |
| ប្រាក់ខែទទួលបានសរុប | គ្មាន |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរ និងកេងប្រវ័ញ្ចពលកម្ម:<br>- មិនផ្តល់ប្រាក់ខែឲ្យ<br>- ធ្វើការ ២០ ម៉ោងក្នុងមួយថ្ងៃ |
| ភ្នាក់ងារជ្រើសរើស | Giant Ocean International Fishery Co., Ltd |
| ថ្ងៃខែបំពេញពាក្យបណ្តឹង | ០៦ ខែកក្កដា ឆ្នាំ ២០១២ ផ្តឹងដោយម្តាយជនរងគ្រោះ |
| សំណងដែលទាមទារ | ៦៩០០ ដុល្លារអាមេរិក |
| សេវាដែលទទួលការគាំទ្រពី CTIP II | -សេវាផ្នែកច្បាប់ និងពិគ្រោះយោបល់<br>-ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីតំណាង |

| | |
|---|---|
| | ឲ្យជនរងគ្រោះនៅពេលដំណើរការក្តី<br>-ជួយជនរងគ្រោះក្នុងការរៀបចំកិច្ចសម្ភាសន៍ និងដាក់ ពាក្យបណ្តឹងទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ |

ជនរងគ្រោះអាយុ៣១ឆ្នាំ មកពីរាជធានីភ្នំពេញ។ គាត់ចាកចេញពីប្រទេសតាមរយៈក្រុមហ៊ុន Giant Ocean International Fishery Co., Ltdទៅធ្វើការតាមកប៉ាល់នេសាទក្នុងទីក្រុងខែប។ នៅពេលគាត់មកដល់កប៉ាល់នេសាទភ្លាម កប៉ាល់ក៏ចេញដំណើរពីក្រុងខែបទៅកណ្តាលសមុទ្រ។ នៅលើទូក គាត់ត្រូវបានគេវាយធ្វើបាប និងបង្ខំធ្វើការយ៉ាងធ្ងន់ធ្ងរ ប្រហែល ២០ម៉ោងក្នុងមួយថ្ងៃ។ គាត់មិនត្រូវបានអនុញ្ញាតិចុះពីលើទូកទេ។ គាត់រាយការណ៍ថា គាត់មិនដែលបានទទួលថ្នាំព្យាបាល ហើយប្រឈមនឹងគ្រោះថ្នាក់គ្រប់ពេលវេលា។

ជនរងគ្រោះរាយការណ៏ថា ថ្ងៃមួយ កប៉ាល់នេសាទបានចូលចតនៅកំពង់ផែ កៅសៀង ( Kaohsiung ) នៅតៃវ៉ាន់។ ម្តាយរបស់គាត់ដឹងពីស្ថានភាពគ្រោះថ្នាក់នេះ គាត់ក៏បានដាក់ពាក្យបណ្តឹងទៅអង្គការ LSCW ប្រឆាំងនឹងភ្នាក់ងារជ្រើសរើសពលករ នឹងសុំឲ្យកូនរបស់គាត់ត្រឡប់មកវិញ នៅថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០១២។ ដូច្នេះអង្គការ LSCW បានធ្វើអន្តរាគមន៍តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃកម្ពុជា។ ជាចុងក្រោយ ជនរងគ្រោះបានធ្វើមាតុភូមិនិវត្ត នៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០១២។

## ប្រទេសអាហ្វ្រិកខាងត្បូង ករណីទី៧

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ ១នាក់ មកពីខេត្តកំពង់ចាម |
| គោលដៅ | ប្រទេសអាហ្វ្រិកខាងត្បូង |
| ថ្ងៃចេញដំណើរ | ០៧ ខែកញ្ញា ឆ្នាំ ២០១០ |
| ថ្ងៃវិលត្រឡប់ | ២១ ខែ កក្កដា ឆ្នាំ ២០១២ |
| ប្រាក់ខែដែលសន្យាឲ្យ | ២០០ ដុល្លារអាមេរិក ក្នុងមួយខែ |
| ប្រាក់ខែទទួលបានសរុប | មិនទទួលបានប្រាក់ខែទាល់តែសោះ។ នាយនាវីកបានចេញថ្លៃសំបុត្រយន្តហោះឲ្យជនរងគ្រោះត្រឡប់មកផ្ទះវិញ និង ប្រាប់ជនរងគ្រោះថាប្រាក់ខែរបស់គាត់នឹងបញ្ជូនតាមក្រុមហ៊ុន Giant Ocean ក្នុងប្រទេសកម្ពុជា |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរ និងកេងប្រវ័ញ្ចកំលាំងពលកម្ម<br>- មិនផ្តល់ប្រាក់ខែឲ្យ<br>- ធ្វើការ ច្រើនជាង២០ម៉ោងក្នុងមួយថ្ងៃ<br>- ខ្វះអាហារ<br>- រំលោភបំពានដល់រាងកាយ |
| ភ្នាក់ងារជ្រើសរើសពលករ | ក្រុមហ៊ុន Giant Ocean |
| ថ្ងៃខែបំពេញពាក្យបណ្តឹង | ២៤ ខែកក្កដា ឆ្នាំ ២០១២ |
| សំណងដែលទាមទារ | ៦៩០០ ដុល្លារអាមេរិក |

| | |
|---|---|
| សេវាដែលទទួលការគាំទ្រពី CTIP II | - ផ្នែកច្បាប់និងពិគ្រោះយោបល់<br>- ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីជាតំណាងឲ្យជនរងគ្រោះនៅពេលដំណើរការក្តី<br>-ជួយជនរងគ្រោះក្នុងការរៀបចំកិច្ចសម្ភាសន៍ និងដាក់ពាក្យបណ្តឹងទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ |

ជនរងគ្រោះមានអាយុ ២៧ឆ្នាំ មកពីខេត្តកំពង់ចាម។ ដោយសារតែភាពក្រីក្រ គាត់បោះបង់ការសិក្សានៅថ្នាក់ទី២ តាំងពីវ័យក្មេង ហើយធ្វើការជាកសិករ។

ក្នុងខែសីហា ឆ្នាំ២០១០ ជនរងគ្រោះបានឮពីព័ត៌មានស្តីពីឱកាសការងារក្នុងប្រទេសសិង្ហបូរី ខណៈពេលគាត់កំពុងស្តាប់វិទ្យុ។ ក្រុមហ៊ុន Giant Ocean បានផ្សាយពាណិជ្ជកម្មតាមវិទ្យុថា ភ្នាក់ងារជ្រើសរើសពលករ នឹងផ្តល់ប្រាក់ខែ ២០០ ដុល្លារអាមេរិកក្នុងមួយខែទៅដល់ពលករ។ ពេលនោះ ជនរងគ្រោះ មិនបានដឹងថាគាត់ត្រូវគេបោកប្រាស់ទេ។ ដូច្នេះ គាត់សម្រេចថាទទួលយកឱកាសការងារដ៏ល្អនេះ ហើយគាត់ក៏ចាប់យកការងារនេះ។ គាត់បានមកការិយាល័យ ភ្នាក់ងារជ្រើសរើសពលករនៅភ្នំពេញ ហើយចុះឈ្មោះទទួលធ្វើការងារនោះ។

តាមរយៈជនរងគ្រោះ ភ្នាក់ងារជ្រើសរើសពលករ បានសន្យាថាឲ្យគាត់ទៅធ្វើការនៅប្រទេសសិង្ហបូរី ជាកម្មករនេសាទ។ ទោះបីយ៉ាងណា ពួកគេមិនបានពន្យល់ពីលក្ខខណ្ឌការងារ ឬការងារនេសាទអ្វី ដែលគាត់នឹងត្រូវធ្វើនោះទេ។ ពួកគេបានផ្តល់ប្រាក់ខែ ១៥០ ដុល្លារអាមេរិកក្នុងមួយខែ ដែលបែងចែកដូចតទៅ៖ ៥០ដុល្លារ អាមេរិកឲ្យទៅគាត់ផ្ទាល់

៥០ដុល្លារអាមេរិកទៀតឲ្យទៅគ្រួសារនៅប្រទេសកម្ពុជា និងនៅសល់ ៥០ ដុល្លារអាមេរិកទៀតដាក់ក្នុងគណនីធនាគារនៅកម្ពុជា។ ភ្នាក់ងារជ្រើសរើសពលករបានប្រាប់គាត់ថា ពួកគេនឹងជួយគ្រួសារគាត់បើកគណនីនៅធនាគារ អេស៊ីលីដា ប៉ុន្តែជាក់ស្តែងពួកគេមិនដែលបានបើកគណនីធនាគារដើម្បីដាក់ប្រាក់ចំនួន ៥០ដុល្លាអាមេរិកឲ្យគាត់ទេ ហើយក៏មិនដែលបានទូទាត់ប្រាក់ប្រចាំខែចំនួន ៥០ដុល្លាអាមេរិកផ្សេងទៀតដល់ក្រុមគ្រួសាររបស់គាត់ដូចដែលបានសន្យានោះដែរ។ ជនរងគ្រោះមិនដែលបានទទួលប្រាក់ ៥០ ដុល្លារអាមេរិកដូចសន្យានឹងគាត់ទេ ហើយម្ចាស់ទូក (ប្រធានក្រុមទូក) បានប្រាប់គាត់ថា ចំនួនប្រាក់នោះ ទុកទិញសំបុត្រយន្តហោះត្រឡប់មកប្រទេសកម្ពុជាវិញ ពេលកិច្ចសន្យាការងារត្រូវបានបញ្ចប់។

បន្ទាប់ពីជនរងគ្រោះបានចុះឈ្មោះជាមួយក្រុមហ៊ុន Giant Ocean ហើយ គាត់បានទៅខេត្តកំពង់ចាមវិញ ដើម្បីប្រមូលយកឯកសារដែលចាំបាច់ ដើម្បីធ្វើលិខិតឆ្លងដែន។ គាត់បានត្រឡប់ទៅភ្នាក់ងារ ជ្រើសរើសពលករនៅភ្នំពេញ ដើម្បីប្រគល់ឯកសារទាំងនោះឲ្យទៅក្រុមហ៊ុនពិនិត្យ និងបានចុះហត្ថលេខា លើឯកសារអនុញ្ញាតិឲ្យគ្រួសាររបស់គាត់នឹងទទួលប្រាក់ ៥០ដុល្លារអាមេរិកក្នុងមួយខែ ដែលជាចំណែកនៃប្រាក់ខែរបស់គាត់។ គាត់បានទទួលលិខិតឆ្លងដែនរបស់គាត់នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ និងបានចាកចេញពីប្រទេសកម្ពុជានៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០។

គាត់មកដល់ប្រទេសសិង្ហបូរីនៅថ្ងៃដដែល និងស្នាក់នៅក្នុងការិយាល័យភ្នាក់ងារជ្រើសរើសពលករ រហូតដល់គាត់ចេញដំណើរទៅប្រទេសអាហ្វ្រិកខាងត្បូងនៅកណ្តាលអាធ្រាត។ គាត់មិនចងចាំឯកសារដែលចុះហត្ថលេខា នៅឯការិយាល័យភ្នាក់ងារជ្រើសរើសពលករនោះទេ។ ជនរងគ្រោះបានមកដល់ទីក្រុង ខេប ថោន ប្រទេសអាហ្វ្រិកខាងត្បូងមួយថ្ងៃបន្ទាប់។ នៅព្រលានយន្តហោះ មានបុគ្គលិកភ្នាក់ងារជ្រើស

រើសពលករម្នាក់ ជួបជាមួយគាត់ និងនាំគាត់ទៅជួមម្ចាស់កប៉ាល់នេសាទជាជនជាតិតៃវ៉ាន់ ដែលមានឈ្មោះដាហ៊ី។ គាត់ស្នាក់នៅទីនោះរយៈពេល ៤ថ្ងៃ ពេលដែលកប៉ាល់នេសាទចតនៅកំពង់ផែ។ ក្នុងរយៈពេលពីរបីថ្ងៃនោះ គាត់បានជួយយន្តការី ដើម្បីជួសជុលម៉ាស៊ីនកប៉ាល់។

នៅពេលកប៉ាល់នេសាទចូលទៅដល់ទឹកជ្រៅ ការងាររបស់គាត់គឺផ្សេង។ គាត់រៀបចំនុយត្រី ធ្វើត្រី និងប្រមូលត្រីយកទៅក្លាសេទឹកកក។ មានកម្មករ ៤០នាក់នៅលើទូកនេះ កម្ពុជា ២នាក់ ហ្វីលីពីន ៨នាក់ វៀតណាម ៦នាក់ ឥណ្ឌូនេស៊ី ៨នាក់ ប្រុយណេ ២នាក់ ចិន៤នាក់ និងជនជាតិតៃវ៉ាន់ ១០នាក់។ គាត់ និងសមាជិកនេសាទផ្សេងទៀត ធ្វើការលើកប៉ាល់នេសាទ ៧ថ្ងៃក្នុងមួយសប្តាហ៍ និងបានដេកតិចតួច និងពេលខ្លះមិនបានដេកទេ។ ការពិត ពួកគេបានសំរាក តែ៣ទៅ៤ម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ជនរងគ្រោះបានរាយការណ៍ថា ពុំមានអាហារគ្រប់គ្រាន់ សមាជិកនេសាទ ទទួលអាហារតែ ១ដង ឬ២ដងក្នុងមួយថ្ងៃ ហើយមានជម្ងឺដោយខ្វះអាហារ។ លក្ខខណ្ឌរស់នៅមិនប្រសើរទេ។ ជារឿយៗប្រធានក្រុមទូកនេសាទ វាយធ្វើបាបជនរងគ្រោះ ដោយចោទថាធ្វេសប្រហែស និងការងារ និងគំរាមកំហែងសម្លាប់គាត់។

មុនពេល គាត់ត្រូវធ្វើមាតុភូមិនិវត្ត ម្ចាស់ទូក (ពុំស្គាល់អត្តសញ្ញាណច្បាស់) គាត់ព្យាយាមបញ្ជូន ប្រាក់ខែរបស់គាត់ តាមរយៈក្រុមហ៊ុនដែលមិនស្គាល់ឈ្មោះក្នុងប្រទេសសិង្ហបូរី។ បន្ទាប់មក ម្ចាស់ទូកបានឲ្យឯកសារមកគាត់ជាច្រើន រួមទាំងកិច្ចសន្យាការងារដែលសរសេរជាភាសារចិន និងពាក្យផ្ញើរប្រាក់ជាច្រើនពីធនាគារ ដែលបង្ហាញពីការ ទំនាក់ទំនងរវាងភ្នាក់ងារក្រុមហ៊ុនក្នុងប្រទេសសឹង្ហបូរី និងក្រុមហ៊ុន Giant Ocean ក្នុងប្រទេសកម្ពុជា។

ជនរងគ្រោះវិលត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១២។ បច្ចុប្បន្ន គាត់បានសុំឲ្យអ្នកកាន់ច្បាប់នៅកម្ពុជា ដាក់ទោសអ្នកដែលជួញដូរគាត់។ គាត់ ទាមទារប្រាក់សំណងដែលគាត់ត្រូវបានផងដែរប៉ុន្តែគាត់មិនដែលបានទទួលវាទេ។

## ប្រទេសអាហ្វ្រិកខាងត្បូង ករណីទី៨

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ ១នាក់ មកពីខេត្តកំពត |
| គោលដៅ | ប្រទេសអាហ្វ្រិកខាងត្បូង |
| ថ្ងៃចេញដំណើរ | ០៧ ខែតុលា ឆ្នាំ២០១១ |
| ថ្ងៃវិលត្រឡប់ | ៣១ ខែធ្នូ ឆ្នាំ២០១១ |
| ប្រាក់ខែដែលសន្យាឲ្យ | ២០០ ដុល្លារអាមេរិក ក្នុងមួយខែ<br>និងប្រាក់បន្ថែម ២០ ដុល្លាអាមេរិក |
| ប្រាក់ខែទទួលបានសរុប | គ្មាន មានតែសំបុត្រយន្តហោះវិលមកផ្ទះ |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | - មិនផ្តល់ប្រាក់ខែឲ្យ<br>- រំខានពីសមាជិកនេសាទផ្សេងទៀត<br>- ធ្វើការ ១៤ម៉ោងក្នុងមួយថ្ងៃ |
| ភ្នាក់ងារជ្រើសរើសពលករ | Phoenix International Co., Ltd |
| ថ្ងៃខែដាក់ពាក្យបណ្តឹង | ២០ ខែកក្កដា ឆ្នាំ២០១២ |
| សំណងដែលទាមទារ | ៥៦៥០ ដុល្លារអាមេរិក |
| សេវាដែលទទួលការគាំទ្រពី CTIP II | - ទាក់ទងអង្គការអន្តរជាតិទេសប្រវេសន៍ យកជនរង គ្រោះមកវិញ<br>- កំណត់អត្តសញ្ញាណជនរងគ្រោះ ជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស<br>- ផ្តល់សេវាផ្នែកច្បាប់ និងពិគ្រោះយោបល់ |

| | |
|---|---|
| | - ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីជាតំណាងឲ្យជនរងគ្រោះនៅពេលដំណើរការក្តី<br>- ជួយជនរងគ្រោះក្នុងការរៀបចំកិច្ចសម្ភាសន៍ និងដាក់ពាក្យបណ្តឹងទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអានីតិជន នៃក្រសួងមហាផ្ទៃបញ្ជូនទៅរកសេវាជំនាញជួសជុលម៉ូតូ តាមរយៈអង្គការស្ត្រីខ្មែរសហប្រតិបត្តិការដើម្បីអភិវឌ្ឍ |

ថ្ងៃមួយក្នុងខែកញ្ញា ឆ្នាំ ២០១១ ជនរងគ្រោះបានទទួលការមកលេងរបស់បុរសម្នាក់ ដែលជាអ្នកភូមិជិតខាងរបស់គាត់ ដែលបានប្រាប់គាត់ថាឱកាសការងារដែលទទួលបានប្រាក់ខែល្អ។ មេខ្យល់បាន ផ្តល់ការងារឲ្យជនរងគ្រោះធ្វើការងារនេសាទតាមកប៉ាល់នៅប្រទេសជប៉ុន រយៈពេល ២៥ខែ ដោយទទួលប្រាក់ខែ ២០០ដុល្លារអាមេរិកក្នុងមួយខែ និងប្រាក់បន្ថែម ២០ដុល្លារអាមេរិក។ លើសពីនេះ មេខ្យល់ បានឲ្យប្រាក់ ៦៥ដុល្លារអាមេរិក ទៅគាត់ ដែលក្រោយមក នឹងកាត់យកប្រាក់ ១០០ ដុល្លារអាមេរិក ដែលភ្នាក់ងារជ្រើសរើសពលករឲ្យទៅគ្រួសារ នៅព្រលានយន្តហោះភ្នំពេញ មុនពេលជនរងគ្រោះចេញដំណើរ។ ដោយការប្រមើលឃើញថានឹងទទួលបានអនាគតល្អ ជនរងគ្រោះបានទទួលយកឱកាសការងារនោះដោយពុំបានចុះហត្ថលេខាលើកិច្ចសន្យាការងារជាលាយលក្ខអក្សរនោះទេ។

ជនរងគ្រោះបានចេញពីភូមិរបស់គាត់នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០១១ ដោយរថយន្តក្រុង ជាមួយជនចំណាកស្រុកផ្សេងទៀត ដើម្បីទៅ

ភ្នំពេញ ដោយចំណាយប្រាក់ ១០០០០ រៀល (២.៥ ដុល្លារអាមេរិក) ។ រថយន្តក្រុងឈប់នៅការិយាល័យភ្នាក់ងារជ្រើសរើសពលករ របស់ក្រុមហ៊ុន Phoenix International Co., Ltd កន្លែងដែលកម្មករ ត្រូវគេនាំចូលទៅ ហើយចាក់សោទុក។ នៅថ្ងៃទី០៧ ខែតុលា ភ្នាក់ងារជ្រើសរើសពលករ បាននាំជនរងគ្រោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ ជនរងគ្រោះ បានធ្វើដំណើរទៅទីក្រុងបាងកក ហើយជាចុងក្រោយដល់ទីក្រុង ខែប ថោន នៃប្រទេសអាហ្វ្រិកខាងត្បូង កន្លែងដែលប្រហែលជាបុរសជនជាតិ ចិនតៃវ៉ាន់ បានមកទទួលគាត់ និងនាំទៅការិយាល័យនៅតំបន់កំពង់ផែ កន្លែងដែល ប្រធានក្រុមទូកដកហូតយកលិខិតឆ្លងដែនគាត់។

ដូចជាប់អន្ទាក់លើទូក ជនរងគ្រោះ ធ្វើការក្នុងលក្ខខណ្ឌដូចទាសភាព រយៈពេល ២ខែ ដោយធ្វើការ ១៤ម៉ោង ក្នុងមួយថ្ងៃ។ គាត់ទទួលខុសត្រូវជួសជុលសំណាញ់ និងសំអាតទូក។ គាត់មិនដែលទទួលបានប្រាក់ខែរបស់គាត់ទេ។ គាត់ត្រូវបានកម្មករផ្សេងទៀតសម្លុត រំលោភបំពាន និងវាយធ្វើបាប ២ដង ដោយពុំមានអន្តរាគមន៍ពីប្រធានក្រុមទូក ទេហើយ គាត់ពុំមានលទ្ធភាពប្តឹងទៅនរណាម្នាក់បានដែរ។ គាត់ដេកក្នុងបន្ទប់តូចចង្អៀតជាមួយកម្មករ ៣នាក់ លើគ្រែតូចៗ ធ្វើពីដែក។

ដោយលក្ខខណ្ឌរស់នៅនោះមិនអាចទ្រាំទ្របាន និងលក្ខខណ្ឌការងារធ្វើការអស់កម្លាំងពេក ជនរងគ្រោះសម្រេចចិត្តចាកចេញ។ តែទោះបីយ៉ាងណា វាមិនអាចរត់ចេញបានទេ ដោយសារប្រធានក្រុមទូកបានដកហូតលិខិតឆ្លងដែនគាត់ ចាប់តាំងពីគាត់ចុះទូក។ ដោយសារពុំមានលិខិតឆ្លងដែន និងប្រាក់ គាត់មិនដឹងធ្វើយ៉ាងណាដើម្បីត្រឡប់មកវិញបានទេ។

នៅថ្ងៃមួយ ជនរងគ្រោះបានព្យាយាមទាក់ទងមកឪពុករបស់គាត់ នៅខេត្តកំពត ជាអ្នកដែលសុំជំនួយពីក្រុមបុគ្គលិករបស់អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រីនិងកុមារ ដែលអនុវត្តគម្រោង CTIP II ជួយកូនរបស់គាត់។ អង្គការនេះ បានទាក់ទងទៅអង្គការអន្តរជាតិទេសប្រវេសន៍ ក្នុងប្រទេសអាហ្វ្រិកខាងត្បូង ជួយធ្វើមាតុភូមិនិវត្ត។ ជាចុងក្រោយ ជនរងគ្រោះបានធ្វើមាតុភូមិនិវត្តមកប្រទេសកម្ពុជាវិញនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១១។ នៅថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១២ គាត់បានទាក់ទងមក អង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រីនិងកុមារ ។ បុគ្គលិកនៃអង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រីនិងកុមារ បានធ្វើដំណើរមកភូមិរបស់គាត់ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១២ ដើម្បីជួបគាត់ និងកំណត់អត្តសញ្ញាណគាត់ជាជនរង គ្រោះនៃអំពើជួញដូរមនុស្ស និងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការរបស់គាត់។ ក្រុម CTIP II បានផ្តល់សេវាផ្នែកច្បាប់ក្នុងការដាក់បណ្តឹងរបស់គាត់ទៅតុលាការរាជធានីភ្នំពេញ៕ យោងតាមតម្រូវការរបស់ជនរងគ្រោះក្រុម CTIP II ជាចុងក្រោយ បានបញ្ជូនជនរងគ្រោះទៅអង្គការដៃគូមិនមែនរដ្ឋាភិបាល ឈ្មោះស្ត្រីខ្មែរសហប្រតិបត្តិការដើម្បីអភិវឌ្ឍ ដើម្បីរៀនជំនាញជួសជុលម៉ូតូ។ បច្ចុប្បន្នជនរងគ្រោះបានបើកកន្លែងជួសជុលម៉ូតូ។

គាត់បាននិយាយដោយផ្ទាល់ថា "អរគុណជាខ្លាំងដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ដែលបានផ្តល់ជំនួយហិរញ្ញវត្ថុជួយដល់ខ្ញុំ។ បើពុំមានលោកទេ ខ្ញុំមិនអាចវិលត្រឡប់មកប្រទេសកម្ពុជាវិញបានទេ ហើយខ្ញុំក៏មិនប្រាដកថាជីវិតរបស់ខ្ញុំនឹងទៅជាយ៉ាងណាដែរ។ ឥឡូវខ្ញុំមានមុខរបរ ហើយខ្ញុំសង្ឃឹមថា មុខរបរនេះនឹងជួយគាំទ្រគ្រួសាររបស់ខ្ញុំ។

## ប្រទេសហ្វីជី

| | |
|---|---|
| ចំនួនជនរងគ្រោះនិងស្រុកកំណើត | ជនរងគ្រោះ ៣នាក់ មកពីរាជធានីភ្នំពេញ |
| ទិសដៅ | ប្រទេសហ្វីជី |
| ថ្ងៃចេញដំណើរ | ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១១ |
| ថ្ងៃវិលត្រឡប់ | ខែសីហា ឆ្នាំ២០១២ |
| ប្រាក់ខែដែលសន្យា | ១៥០ ដុល្លារអាមេរិកក្នុងមួយខែ |
| ប្រាក់ខែសរុបទទួលបាន | ៤៥០ ដុល្លារអាមេរិក + ១៧៤/១៩០ នៅលើទូក (អាស្រ័យ លើជនរងគ្រោះ) |
| ប្រភេទគ្រោះថ្នាក់ដែលជួបប្រទះ | ជួញដូរមនុស្សឆ្លងដែន និងកេងប្រវ័ញ្ចពលកម្ម<br>- ធ្វើការ ១៩ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍<br>- មិនផ្តល់ប្រាក់ខែឲ្យ |
| ភ្នាក់ងារជ្រើសរើស | ក្រុមហ៊ុន Haoyuen International Co.,Ltd. (H.Y.)និង Giant Ocean International Fishery Co., Ltd. |
| ថ្ងៃខែបំពេញពាក្យបណ្តឹង | ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ |
| សំណងដែលទាមទារ | ៤៩០០ ដុល្លារអាមេរិកក្នុងជនរងគ្រោះម្នាក់ |
| សេវាដែលទទួលការគាំទ្រពី CTIP II | ផ្នែកច្បាប់និងពិគ្រោះយោបល់<br>- ផ្តល់មេធាវីដោយមិនយកកម្រៃដើម្បីនាំជនរងគ្រោះទៅតុលាការ<br>-ជួយជនរងគ្រោះទៅសម្ភាសន៍ និងដាក់ពាក្យបណ្តឹងទៅប៉ូលីសនៃនាយកដ្ឋានយុត្តិធម៌ និងប្រឆាំងការជួញដូរមនុស្សនៃក្រសួង មហាផ្ទៃ |

ជនរងគ្រោះកម្ពុជា ៣នាក់មកពីខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលជ្រើសរើសដោយក្រុមហ៊ុន Haoyuen International Co., Ltd. (H.Y.) នៅឆ្នាំ ២០១១ ហើយបញ្ជូនទៅធ្វើការងារនេសាទក្នុងប្រទេសជប៉ុន។ ការិយាល័យរបស់ក្រុមហ៊ុនេះ និងការិយាល័យរបស់ក្រុមហ៊ុន Phoenix International Co., Ltd មានទីតាំងក្នុងខ័ណ្ឌដូចគ្នា នៅជិតផ្សារដីហុយ។

ជនរងគ្រោះ ៣នាក់ដែលបានសម្ភាសន៍ រាយការណ៍ថា ពួកគេជ្រើសរើសដោយ ស្ត្រីជនជាតិកម្ពុជា ២នាក់ ដែលបានមកភូមិរបស់គេ ដើម្បប្រកាសឱកាសការងារផ្នែកនេសាទតាមកប៉ាល់។ បុរសទាំងនោះបានទទួលយកកាងារនេះ។ ពួកគេបានចំណាយពេល ២សប្តាហ៍នៅការិយាល័យរបស់ក្រុមហ៊ុន Phoenix International Co., Ltd ដើម្បីបណ្តុះបណ្តាល ពួកគេបានរៀនភាសារអង់គ្លេស និងមើលរូបថត ពីអ្វីដែលពួកគេត្រូវធ្វើការងារនេសាទតាមកប៉ាល់ ។ ពួកគេទាក់ទងជាមួយគ្រូបណ្តុះបណ្តាល ៣នាក់ ចុងភៅ ២នាក់ អ្នកគ្រប់គ្រង ២នាក់ និងពីរបីនាក់ទៀត ទំនងជាជនជាតិចិន។ គ្រូបណ្តុះបណ្តាល ១នាក់ គឺលោក ឆាយ បានឲ្យនាមប័ណ្ណក្រុមហ៊ុន Giant Ocean International Fishery Co., Ltd. របស់លោក ដែម សុធី ទៅឲ្យពួកគេ ហើយប្រាប់ថាបុរសនេះជាអ្នកទទួលខុសត្រូវដកយកប្រាក់ ពីគ្រួសារជនរងគ្រោះនៅប្រទេសកម្ពុជា។ មានឈ្មោះភ្នាក់ងារជ្រើសរើសផ្សេងគ្នា ដែលបញ្ជូនពលករកម្ពុជាទៅធ្វើការងារនេសាទតាមកប៉ាល់ ពោលគឺ ក្រុមហ៊ុន Haoyuen International Co., Ltd. (H.Y.) ក្រុមហ៊ុន Phoenix International Co., Ltd និង Giant Ocean International Fishery Co., Ltd. និងទំនាក់ទំនងរវាងក្រុមហ៊ុនទាំងនោះមិនច្បាស់លាស់។ ក្រុមហ៊ុន មានទីតាំងការិយាល័យដូចគ្នា។ ក្នុងករណីនេះ មុនដំបូងជនរងគ្រោះចុះឈ្មោះជាមួយក្រុមហ៊ុន Haoyuen International Co., Ltd. (H.Y.) ប៉ុន្តែជាចុងក្រោយឯកសារខ្លះរបស់ពួកគេ គឺរៀបចំដោយក្រុមហ៊ុន Giant Ocean International Fishery Co., Ltd.។

ជនរងគ្រោះបានចុះហត្ថលេខាលើឯកសារធម្មតាមួយ គឺជាកិច្ចសន្យាការងារដែលពួកគេមិនមានលទ្ធភាពផ្ទៀងផ្ទាត់ទេ ពីព្រោះឯកសារនេះគឺសរសេរជាភាសាអង់គ្លេសទាំងអស់។ ភ្នាក់ងារជ្រើសរើសពលករមិនបានពន្យល់ពួកគេអំពីលក្ខខណ្ឌការងារណាមួយទេ។ លោកឆាយ បានសង្ខេបប្រាប់ពួកគេថា ពួកគេនឹងត្រូវទៅជប៉ុនរយៈពេលបីឆ្នាំ ហើយនឹងរកប្រាក់បាន ១៥០ដុល្លារអាមេរិកក្នុងមួយខែ៖ ក្នុងនោះ ៥០ដុល្លា ក្នុងមួយខែនឹងត្រូវផ្ញើមកឲ្យគ្រួសាររបស់ពួកគេនៅកម្ពុជា (ដែលពួកគេអាចដកប្រើប្រាស់បានរៀងរាល់បីខែម្តង) ២០ដុល្លា ក្នុងមួយខែនឹងត្រូវចំណាយផ្ទាល់ឲ្យពួកគេនៅលើទូកនេសាទ ហើយ ៨០ ដុល្លានឹងត្រូវសន្សំទុកក្នុងគណនីធនាគារសម្រាប់ពួកគេដែលអាចដកលុយនេះនៅពេលបញ្ចប់កិច្ចសន្យាការងារ។ បុរសទាំងនោះត្រូវបានគេប្រាប់ឲ្យចុះហត្ថលេខាលើឯកសារដែលលោកឆាយបានប្រាប់ពួកគេថាទុកជាការព្រមព្រៀងមួយដើម្បីកាត់ ៣០ដុល្លារក្នុងមួយខែពីប្រាក់ខែរបស់ពួកគេសម្រាប់ទិញសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ចាំបាច់មួយចំនួន។ ចំពោះលុយជាក់ស្តែងដែលគ្រួសារបានទទួល ពួកគេបានរាយការណ៍ថាបានទទួលត្រឹមតែ១៥០ដុល្លារសហរដ្ឋអាមេរិកប៉ុណ្ណោះ បន្ទាប់ពីជនរងគ្រោះបានចាប់ផ្តើមធ្វើការក្នុងរយៈពេលបីខែដំបូង ហើយក្រោយៗមកទៀតមិនដែលបានទទួលអ្វីទាំងអស់។

ជនរងគ្រោះទាំងនោះបានចេញដំណើរពីកម្ពុជានៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ ហើយនៅពេលទៅដល់ពួកគេត្រូវបានបញ្ជូនទៅកាន់ទូកនេសាទមួយដែលហៅថា "ហ្សីនលុង លេខ ២១៦"។ ពេលទៅដល់ភ្លាមមេក្រុមទូកក៏បានដកហូតលិខិតឆ្លងដែនរបស់ជនរងគ្រោះទាំងនោះយកទៅរក្សាទុក។ ជនរងគ្រោះទាំងនោះ ក៏ត្រូវបានគេបង្ខឹកនៅទីនោះពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១ និង ក្រោយមកទូកនោះក៏បានចេញដំណើរពីប្រទេសដែនកោះ ហ្វីជី នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១ នោះដែរ

ហើយមិនដែលបានចូលចតនៅកន្លែង ណាទៀតទេ ដែលធ្វើដំណើររហូតដល់ កៅហ្ស៊ីអ៊ុង នៃដែនកោះតៃវ៉ាន់ ក្នុងខែសីហា ឆ្នាំ ២០១២ តែម្តង។

នៅលើទូកនេសាទនោះមានអ្នកនេសាទសរុបទាំងអស់ ២៧នាក់ ៖ ហ្វីលីពីន ៧នាក់ ឥណ្ឌូនេស៊ី ៨នាក់ វៀតណាម ៤នាក់ កម្ពុជា ៤នាក់ និងចិន ៤នាក់។ ប្រធានក្រុមទូកបានបង្ហាញអត្តសញ្ញាណខ្លួនឯងថាជាជនជាតិចិនតៃវ៉ាន់។

នៅលើទូក ជនរងគ្រោះទាំងនោះបានធ្វើការប្រមាណ ១៩ម៉ោងក្នុងមួយថ្ងៃ ហើយជារៀងរាល់ថ្ងៃ ក្នុងមួយសប្តាហ៍។ ពួកគេបានធ្លាក់ខ្លួនឈឺជាច្រើនដង ប៉ុន្តែត្រូវបានគេឲ្យថ្នាំលេប ហើយបង្ខំឲ្យធ្វើការទោះបីជាពួកគេឈឺក៏ដោយ។ ពួកគេមិនដែលសុំត្រឡប់មកកម្ពុជាវិញទេ ពីព្រោះពួកគេតែងតែគិតថា គ្រួសាររបស់ពួកគេបានទទួលប្រាក់ខែដូចដែលគេបានសន្យាផ្តល់ឲ្យពួកគេតាំងពីដំបូង។ ពួកគេមិនបានដឹងថា តាមការពិតក្រុមហ៊ុន Haoyuen International Co., Ltd. (H.Y.) និង Giant Ocean International Fishery Co.,Ltd. ត្រូវបានបិទទ្វារចោល ដើម្បីកុំឲ្យគ្រួសាររបស់ពួកគេអាចមកបើកលុយបាននោះទេ។

នៅពេលទូកនេសាទរបស់ពួកគេបានចតនៅ កៅហ្ស៊ីអ៊ុង នៃដែនកោះតៃវ៉ាន់ មេក្រុមទូកបានប្រាប់ឲ្យជនរងគ្រោះទាំងនោះជញ្ជូនត្រីដែលពួកគេបានចាប់ចេញពីទូក។ ការងារនេះបានធ្វើឲ្យពួកគេមានឱកាសទាក់ទងមកគ្រួសាររបស់ពួកគេនៅកម្ពុជា។ នៅពេលដែលគ្រួសាររបស់ពួកគេប្រាប់ថា ភ្នាក់ងារជ្រើសរើសពលករបានបិទទ្វារ ហើយពួកគេបានទទួលលុយត្រឹមតែ ១៥០ដុល្លារអាមេរិកប៉ុណ្ណោះ ជនរងគ្រោះទាំងនោះបានប្រាប់ឲ្យមេក្រុមទូកបញ្ជូនពួកគេត្រឡប់មកកម្ពុជាវិញ។ ពីដំបូងមេក្រុមទូកបានបដិសេធ ប៉ុន្តែក្រោយមកបានយល់ព្រមបញ្ជូនពួកគេត្រឡប់មកស្រុកវិញដោយប្រាប់ពួកគេថា លិខិតឆ្លងដែន និងថ្លៃសំបុត្រយន្តហោះបានបង់រួច

ហើយតាមរយៈលុយ ៣០ដុល្លារក្នុងមួយខែដែលបានកាត់ពីប្រាក់ខែរបស់ពួកគេ។ ជនរងគ្រោះម្នាក់បានរាយការណ៍ថា បានទទួលលុយសរុបទាំងអស់ត្រឹមតែ ១៧៤ដុល្លា ពីការងារលើទូក ក្នុងខណៈដែលជនរងគ្រោះម្នាក់ទៀតបានប្រាប់ថា បានទទួលលុយត្រឹមតែ១៩០ដុល្លារប៉ុណ្ណោះ។

ជនរងគ្រោះទាំងនោះបានរាយការណ៍ថា បានឃើញអ្នកនេសាទជនជាតិកម្ពុជាជាច្រើននៅកំពង់ផែកៅហ្ស៊ីអ៊ុង ប៉ុន្តែពួកគេមិនចាំឈ្មោះនិងព័ត៌មានទំនាក់ទំនង។

# ឧបសម្ព័ន្ធ ១៖ ផែនទីបង្ហាញពីផ្លូវធ្វើដំណើររបស់អ្នកនេសាទនៃករណីសិក្សាទាំងនេះ

**Annex 1:** *Map illustrating the journeys of the fishermen of the case studies*



## ឧបសម្ព័ន្ធ ២៖ រូបភាពនៃប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន Giant Ocean International Fishery Co., Ltd. ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**Annex 2:** *Picture of the license of Giant Ocean International Fishery Co., Ltd by the Ministry of Economy and Finance*



## ឧបសម្ព័ន្ធ ៣៖ រូបភាពនៃវិញ្ញាបនប័ត្ររបស់ក្រុមហ៊ុន Giant Ocean International Fishery Co., Ltd.ដែលចេញដោយក្រសួងពាណិជ្ជកម្ម

**Annex 3:** *Picture of the license of Giant Ocean International Fishery Co., Ltd by the Ministry of Commerce*



## ឧបសម្ព័ន្ធ ៤៖ រូបភាពនៃប័ណ្ណចំណាយដែលសន្យាផ្តល់ឲ្យ ដោយក្រុមហ៊ុន

Giant Ocean International Fishery Co., Ltd.

**Annex 4:** *Picture of the pay slips promised to a victim of Giant Ocean International Fishery Co., Ltd.*



ឧបសម្ព័ន្ធ ៥៖ រូបភាពកំណត់ត្រារបស់ក្រុមហ៊ុន Giant Ocean International Fishery Co., Ltd.

**Annex 5:** *Picture of a seaman's book of a victim of Giant Ocean International Fishery Co., Ltd.*









# ឧបសម្ព័ន្ធ ១៖ ផែនទីបង្ហាញពីផ្លូវធ្វើដំណើររបស់អ្នកនេសាទនៃករណីសិក្សាទាំងនេះ

**Annex 1:** *Map illustrating the journeys of the fishermen of the case studies*



**ឧបសម្ព័ន្ធ ២៖** រូបភាពនៃប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន Giant Ocean International Fishery Co., Ltd.

ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**Annex 2:** *Picture of the license of Giant Ocean International Fishery Co., Ltd by the Ministry of Economy and Finance*



## ឧបសម្ព័ន្ធ ៣៖ រូបភាពនៃវិញ្ញាបនប័ត្ររបស់ក្រុមហ៊ុន Giant Ocean International Fishery Co., Ltd.ដែលចេញដោយក្រសួងពាណិជ្ជកម្ម

**Annex 3:** *Picture of the license of Giant Ocean International Fishery Co., Ltd by the Ministry of Commerce*



# ឧបសម្ព័ន្ធ ៤៖ រូបភាពនៃប័ណ្ណចំណាយដែលសន្យាផ្តល់ឲ្យ ដោយក្រុមហ៊ុន

Giant Ocean International Fishery Co., Ltd.

**Annex 4:** *Picture of the pay slips promised to a victim of Giant Ocean International Fishery Co., Ltd.*



## ឧបសម្ព័ន្ធ ៥៖ រូបភាពកំណត់ត្រារបស់ក្រុមហ៊ុន Giant Ocean International Fishery Co., Ltd.

**Annex 5:** *Picture of a seaman's book of a victim of Giant Ocean International Fishery Co., Ltd.*






